AFESIP

AGIR POUR LES FEMMES
EN SITUATION PRÉCAIRE

# របាយការណ៍ ប្រចាំឆ្នាំ ២០២៤




ទំនាក់ទំនង

ទូរស័ព្ទដៃលេខ: +៨៥៥ (០)៦១៦០១៦០១/ (០)១២៨៨៨៨៤០

អ៊ីម៉ែល: **info@afesip.org**

គេហទំព័រ: **afesip.org**

# មាតិកា ទំព័រ


| មាតិកា | ទំព័រ |
|---|---|
| ១. សារពីលោកស្រីស្ថាបនិក និងអគ្គនាយិកា | ៣ |
| ២. អាហ្វេស៊ីប កម្ពុជា | ៤ |
| ៣. សកម្មភាពសំខាន់ៗប្រចាំខែ | ៥ |
| ៤. របាយការណ៍សង្ខេប | ៦ |
| ៥. ករណីជោគជ័យ យុវនារីទទួលផលពីគំរោងកម្មវិធី | ៧ |
| ៦. មណ្ឌល ទុំឌី | ៨ |
| ៧. កម្មវិធីថែទាំសុខភាព | ៩-១០ |
| ៨. កម្មវិធីចិត្តសាស្ត្រ (សុខភាពផ្លូវចិត្ត) | ១០-១១ |
| ៩. កម្មវិធីជំនួយនីតិកម្ម | ១២ |
| ១០. កម្មវិធីអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ | ១៣-២០ |
| ១១. កម្មវិធីលើកកម្ពស់សេដ្ឋកិច្ច និងសមាហរណកម្ម | ២០-២១ |
| ១២. កម្មវិធីលើកកម្ពស់អតីតជនរងគ្រោះ (សែន) | ២២-២៣ |
| ១៣. បុគ្គលិក និងការគ្រប់គ្រងគម្រោង | ២៣-២៤ |
| ១៤. ផែនការឆ្នាំ២០២៥ | ២៥ |
| ១៥. ក្រុមប្រឹក្សាភិបាល | ២៦ |
| ១៦. របាយការណ៍សង្ខេបអំពីហិរញ្ញវត្ថុ | ២៧ |
| ១៧. ម្ចាស់ជំនួយ | ២៨ |

# សារពីលោកស្រីស្ថាបនិក និងអគ្គនាយិកា



សួស្តីមិត្តៗទាំងអស់ជាទីរាប់អាន

សួស្តីឆ្នាំថ្មីអ្នកទាំងអស់គ្នា សូមមានសំណាងល្អក្នុងឆ្នាំ២០២៥

ជាធម្មតា នៅចុងឆ្នាំនីមួយៗ យើងជម្រាបជូនអ្នកគាំទ្រការងារយើង អំពីរបាយការណ៍សកម្មភាពប្រចាំឆ្នាំ របស់អង្គការ អាហ្វេស៊ីប កម្ពុជា ដោយបន្លិចនូវសមិទ្ធិផលសម្រេចបាន បញ្ហាប្រឈមក្នុងការអនុវត្តការងារនាឆ្នាំកន្លងទៅ និងកម្រិតសមិទ្ធិផលសម្រេចបានក្នុងឆ្នាំ២០២៤ ដើម្បីបង្ហាញអំពីការងាររបស់យើង។

សូចនាករនៃកម្មវិធីនីមួយៗដែលយើងបានដាក់ចេញ យើងបានអនុវត្តទទួលបានលទ្ធផលល្អសឹងតែទាំងអស់ ដោយអនុលោមតាមទិសដៅរួម និងចក្ខុវិស័យអង្គការ។

លទ្ធផលការងារសម្រេចបានដ៏ត្រចះត្រចង់ទាំងនេះ នឹងមិនអាចសម្រេចបានឡើយ ប្រសិនបើគ្មានការចូលរួមចំណែក ពីសំណាក់លោក-លោកស្រីទេនោះ ដូច្នេះយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះលោក-លោកស្រី នាងកញ្ញាទាំងអស់។ ក្នុងនាមអង្គការ អាហ្វេស៊ីប កម្ពុជា យើងខ្ញុំមានមោទនភាពខ្លាំងណាស់ ចំពោះប្រតិបត្តិការដ៏មានតម្លាភាព និងគណនេយ្យភាពរបស់យើង ចំពោះម្ចាស់ជំនួយ និងអ្នកគាំទ្រការងារយើង។ របាយការណ៍នេះបរិយាយលម្អិត អំពីសកម្មភាពការងារប្រចាំឆ្នាំ២០២៤ ក្នុងគោលបំណងបង្ហាញជូនអំពីភាពខុសគ្នានៃផលប៉ះពាល់ជាវិជ្ជមានលើជីវិតកុមារី និងក្រុមគ្រួសារពួកគាត់ដែលយើងបានធ្វើការជាមួយនៅក្នុងប្រទេសកម្ពុជា។

២០២៤ ជាឆ្នាំជោគជ័យមួយទៀត សម្រាប់អង្គការ អាហ្វេស៊ីប កម្ពុជា។ យើងខ្ញុំសូមបង្ហាញជូននូវការបន្តភាពជោគជ័យនៃបណ្តាកម្មវិធីទាំងឡាយ ក្នុងការជួយជីវិតជនរងគ្រោះ និងគ្រួសារពួកគាត់ជាបន្តបន្ទាប់ ករណីជោគជ័យនៃអ្នកទទួលផលពីគម្រោងកម្មវិធីយើង ទឹកចិត្តសប្បុរសពីសំណាក់សហគមន៍យើង និងការអភិវឌ្ឍថ្មីៗនៃបណ្តាកម្មវិធី ដូចជាសិប្បកម្ម បន្តទទួលអាហារូបករណ៍ឧត្តមសិក្សា(ថ្លៃសាលា)ពីរដ្ឋាភិបាលសម្រាប់យុវនារី ចុះកិច្ចព្រមព្រៀងជាមួយក្លឹបបាល់ទាត់អូអ៊ិចយូណៃធីតស្តីអំពីការបណ្តុះបណ្តាលជំនាញបាល់ទាត់មូលដ្ឋានដល់កុមារីចំនួន១៧នាក់ កិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យតៅយ៉ន់មកពីតៃវ៉ាន់ស្តីអំពីការផ្តល់សម្ភារ និងថ្នាំពេទ្យ ជួសជុលចាក់ដីបរិវេណផ្ទះបាយកម្ពស់០,៣ម៉ែត្របន្ថែម ដើម្បីការពារទឹកលិចពេលរដូវវស្សាផ្តល់សុវត្ថិភាពដល់កុមារីនិងបុគ្គលិក បុគ្គលិកអតីតជនរងគ្រោះចំនួន៤នាក់បានបញ្ចូលជាមន្ត្រីរាជការ និងសមាជិកកម្មវិធីបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ (សែន) បានជួយដល់ប្រតិបត្តិការកម្មវិធីទាំងឡាយយ៉ាងសកម្មទាំងនៅក្នុងមណ្ឌល និងនៅតាមសហគមន៍។ យើងបានបញ្ជ្រាបការយល់ដឹងតាមបណ្តាញសង្គមនានា តាមវេទិកាសាធារណៈ និងការចូលរួមប្រជុំផ្សេងៗទាំងថ្នាក់ជាតិនិងអន្តរជាតិ ក្នុងគោលបំណងលើកកម្ពស់ការគាំពារកុមារ។

ករណីជោគជ័យ និងសមិទ្ធិផលសម្រេចបានយ៉ាងល្អនៃបណ្តាកម្មវិធី យើងបានបង្ហាញនៅក្នុងរបាយការណ៍នេះ នឹងមិនអាចសម្រេចបានទេ ប្រសិនបើមិនមានការចូលរួមពីបណ្តាបុគ្គលិក អ្នកស្ម័គ្រចិត្ត សមាជិកក្រុមប្រឹក្សាភិបាល សប្បុរសជន និងដៃគូសហគមន៍ ដ៏ល្អទេនោះ ជាពិសេស គឺការគាំទ្រយើងបន្តទទួលបានពីរាជរដ្ឋាភិបាលកម្ពុជា ជារៀងរហូតមក។ នាងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់អ្នកទាំងអស់គ្នានូវពេលវេលាដ៏មានតម្លៃរបស់អ្នកទាំងអស់គ្នា ការប្តេជ្ញាចិត្ត ការលះបង់ និងឧបត្ថម្ភគាំទ្រជារៀងរហូតមក។ នាងខ្ញុំក៏សូមអរគុណដល់លោកលោកស្រីនាងកញ្ញាសម្រាប់ការអានរបាយការណ៍សកម្មភាពឆ្នាំ២០២៤នេះ នឹងសង្ឃឹមយ៉ាងមុតមាំថានឹងបន្តជួយគាំទ្រដល់ការងាររបស់យើងតាមលទ្ធភាពរបស់លោក-លោកស្រី នាងកញ្ញាដើម្បីឆ្ពោះទៅរកការលុបបំបាត់ការរំលោភបំពាន់កុមារគ្រប់រូបភាពនៅក្នុងសហគមន៍របយើង។

ដោយក្តីរាប់អានដ៏ស្មោះស្ម័គ្រ

AFESIP CAMBODIA
AGIR POUR LES FEMMES EN SITUATION PRECAIRE

**ម៉ម សុម៉ាលី**

# អំពី អាហ្វេស៊ីប កម្ពុជា

**អង្គការ អាហ្វេស៊ីប កម្ពុជា** បានបង្កើតឡើងនៅឆ្នាំ១៩៩៦ ដោយលោកស្រី**ម៉ម សុម៉ាលី** លោកស្រីជាអតីតជនរងគ្រោះដោយការជួញដូរ ក្នុងគោលបំណងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

**ចក្ខុវិស័យ** ជាពិភពលោកមួយដែលកុមារមានសុវត្ថិភាពពីទាសភាព។

**ទិសដៅអង្គការ** ផ្តល់ការថែទាំ និងធានាបាននូវសិទ្ធិរបស់យុវនារី-កុមារីរងគ្រោះ និងងាយរងគ្រោះ ដោយអំពើទាសភាព តាមរយៈការស្តារនីតិសម្បទា ការអប់រំ បណ្តុះបណ្តាល និងសមាហរណកម្មដោយជោគជ័យ ត្រឡប់ទៅសង្គមវិញដោយឯករាជ្យភាពហិរញ្ញវត្ថុ និរន្តរភាព និងភាពថ្លៃថ្នូរ។ យើងអនុវត្តការងារនេះ ដោយជួយជ្រោមជ្រែង និងបង្ហាត់បង្រៀនពួកគាត់ អំពីឯករាជ្យភាពហិរញ្ញវត្ថុ តាមរយៈនិរន្តភាពមុខរបរ។ បន្ទាប់មកយើងស្វាគមន៍ លើកទឹកចិត្តឱ្យពួកគាត់ ក្លាយជាផ្នែកមួយរបស់បណ្តាញលើកកម្ពស់អតីតៈជនរងគ្រោះ ។

**ក្រុមគោលដៅ** កុមារីជនរងគ្រោះ  និងងាយរងគ្រោះ ដោយការជួញដូរ រំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។

## កម្មវិធីយើង



# សកម្មភាពសំខាន់ៗប្រចាំខែ ឆ្នាំ២០២៤

## មករា សម្តេច ហ៊ុន សែន បន្តជួយគាំទ្រ

**សម្តេច ហ៊ុន សែន** (អតីតនាយករដ្ឋមន្ត្រី) ប្រធានព្រឹទ្ធសភា **សម្តេច អគ្គមហាសេនាបតីតេជោ**... 

**សម្តេច ហ៊ុន សែន** (អតីតនាយករដ្ឋមន្ត្រី) ប្រធានព្រឹទ្ធសភា **សម្តេច កិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**ប្រធានកាកបាទក្រហមកម្ពុជា និង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុនី ហ៊ុនម៉ាណែត ស្ត្រីទី១** បានអញ្ជើញមកលេងចៅៗ និងកូនៗ(ខែកញ្ញា)នៅមណ្ឌលទុំឌី។ **សម្តេច** លោកបានប្រកាសថា **គ្រួសារហ៊ុន** នឹងនៅតែបន្តជួយគាំទ្រអង្គការ អាហ្វេស៊ីប កម្ពុជា។

## កុម្ភៈ អនុវត្តតាមបទដ្ឋានអប្បបរមា

យើងបានទទួល (ខែធ្នូ) វិញ្ញាបណ្ណបត្រទទួលស្គាល់មណ្ឌលថែទាំកុមារទុំឌី មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមណ្ឌលថែទាំកុមារ ស្របតាមអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ ពីក្រសួង ស.អ.យ មានសុពលភាព៣ឆ្នាំ។

## មីនា អតីតជនរងគ្រោះជាអ្នកធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន

សមាជិកសកម្មនៃបណ្តាញលើកកម្ពស់អតីតជនរង(សែន)ចំនួន៦៦នាក់ ត្រូវបានជ្រើសរើសជួយដល់បណ្តាការងារកម្មវិធីរបស់យើងទាំងនៅក្នុងមណ្ឌល និងតាមសហគមន៍យ៉ាងសកម្ម។ ឆ្នាំ២០២៤ មានបុគ្គលិកស្ត្រីចំនួន៨៤%ជាអតីតជនរងគ្រោះមានតួនាទីជាគណៈគ្រប់គ្រង និងគណៈគ្រប់គ្រងជាន់ខ្ពស់។

## មេសា បញ្ជ្រៀបការយល់ដឹងដល់សាធារណៈជន

បានរៀបចំយុទ្ធនាការ១សប្តាហ៍ស្តីអំពី#ចែករំលែកក្តីស្រឡាញ់#ផ្តល់ស្នាមញញឹម#អនាគតថ្មី នៅឱកាសខួបកំណើតលោកស្រីស្ថាបនិក និងអគ្គនាយិកា **ម៉ម សុម៉ាលី** ក្នុងគោលបំណងបញ្ជ្រៀបការយល់ដឹងអំពីការការពារបង្ការ និងការគាំពារកុមារ។

## ឧសភា តម្លាភាព និងគណនេយ្យភាព

យើងបានជួលក្រុមហ៊ុនKPMGធ្វើសវនកម្មរបាយការហិរញ្ញវត្ថុប្រចាំ២០២៣របស់យើង នៅខែមេសា ឆ្នាំ២០២៤ គឺដើម្បីត្រួតពិនិត្យ និងវាយតម្លៃអំពីកំណត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុត្រឹមត្រូវ និងច្បាស់លាស់នៃការបង្ហាញកំណត់ត្រារបាយការណ៍ហិរញ្ញវត្ថុ

## មិថុនា ការបញ្ចូលមូលដ្ឋានគ្រឹះភាពជាអ្នកដឹកនាំ

មូលដ្ឋានគ្រឹះភាពជាអ្នកដឹកនាំត្រូវបានដាក់បញ្ចូលក្នុងការអនុវត្តសកម្មភាពការងារប្រចាំថ្ងៃ តាមរយៈវិធីសាស្ត្រនៃការចូលរួមរបស់យុវនារី-កុមារី ដោយការបង្កើតក្រុម-អ្នកដឹកនាំចូលរួមប្រតិបត្តិការសកម្មភាពនៅក្នុងមណ្ឌលទុំឌី។ សមាជិកក្រុម-អ្នកដឹកនាំ ចំនួន៥នាក់ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយយុត្តិធម៌ប្រចាំឆ្នាំរបស់យុវនារី-កុមារីដោយមានការជួយជ្រោមជ្រែងពីបុគ្គលិក។

## កក្កដា ថែទាំសុខភាពផ្លូវចិត្ត និងសុខុមាលភាពបុគ្គលិក

វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពបុគ្គលិក រយៈពេល៣ថ្ងៃ (៩-១១ វិច្ឆិកា)ស្តីអំពីការប៉ះទង្គិចផ្លូវចិត្ត ដោយគ្រូឧទ្ទេសនាមពីCTROសម្រាប់បុគ្គលិកចំនួន២១នាក់ នៅមណ្ឌលទុំឌី។

## សីហា ការងារយើងមានឥទ្ធិពលវិជ្ជមានដល់សាធារណៈជន

ភ្ញៀវចំនួន១,៧៥៩នាក់ ជាសាចញាតិកុមារី ជនបរទេស ក្រុមហ៊ុនសាជីវកម្ម ក្លឹបបាល់ទាត់ ធនាគារ តារាល្បីៗ មន្ត្រីរាជការ និងសាធារណៈជន បានមកសិក្សាស្វែងយល់អំពីការងារយើងនៅមណ្ឌលទុំឌី។

## កញ្ញា ដំណើរទស្សនកិច្ចឆ្ពោះទៅកាន់ខេត្តមណ្ឌលគិរី

ដំណើរទស្សនកិច្ចរយៈពេល៣ថ្ងៃត្រូវបានរៀបចំឡើង សម្រាប់យុវនារី-កុមារីចំនួន៨១នាក់ និងបុគ្គលិកចំនួន២៧នាក់ ឆ្ពោះទៅកាន់ខេត្តមណ្ឌលគិរី ដើម្បីឱ្យពួកគាត់បានលេងកំសាន្តតាមតំបន់រមណីយដ្ឋាននានា ចំការកាហ្វេ ចំការធុរ៉េន និងតាមរមណីយដ្ឋានផ្សេងៗ ក្នុងគោលបំណងឱ្យពួកគាត់បានសិក្សាស្វែងយល់អំពីវប្បធម៌ផ្សេងៗរបស់ជនជាតិភាគតិច។

## តុលា រដ្ឋមន្ត្រីក្រសួង ស.អ.យ បានអញ្ជើញមកទស្សកិច្ច

**ឯ.ឧ ជា សុមេធី រដ្ឋមន្ត្រី** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងលោកជំទាវ បានអញ្ជើញទស្សនកិច្ចសួរសុខទុក្ខសំណេះសំណាលជាមួយយុវនារី-កុមារី និងបុគ្គលិកនៅមណ្ឌលទុំឌី។

## វិច្ឆិកា យើងធ្វើ យើងរៀន

សិក្ខាសាលាពិគ្រោះយោបល់ប្រចាំឆ្នាំរយៈពេល២ថ្ងៃ បានរៀបចំឡើង ដើម្បីពិនិត្យវាយតម្លៃលទ្ធផលការងារ និងបញ្ហាប្រឈមនៃកម្មវិធីនីមួយៗក្នុងឆ្នាំ២០២៤ និងលើកទិសដៅគម្រោងផែនការសកម្មភាពថ្មី និងគម្រោងថវិកាសម្រាប់ឆ្នាំអនុវត្ត២០២៥។

## ធ្នូ ការប្រជុំក្រុមប្រឹក្សាភិបាល

ការប្រជុំក្រុមប្រឹក្សាភិបាល បានរៀបចំឡើង ដើម្បីពិនិត្យវាយតម្លៃ លើលទ្ធផលការងារកម្មវិធីសម្រេចបានក្នុងឆ្នាំអនុវត្ត២០២៤ ធ្វើបទបង្ហាញឆ្លងអនុម័តពីក្រុមប្រឹក្សាភិបាល លើទិសដៅផែនការសកម្មភាពការងារ និងគម្រោងថវិកាឆ្នាំអនុតវត្ត២០២៥។

# របាយការណ៍សង្ខេប

ស្ទើរគ្រប់សូចនាកររំពឹងទុកកម្មវិធីនីមួយៗ ដែលយើងបានដាក់ចេញ សម្រាប់ឆ្នាំ២០២៤ អនុវត្តសម្រេចបានលទ្ធផលល្អប្រសើរ ថ្វីបើយើងជួបបញ្ហាប្រឈមខ្លះៗ។ កម្មវិធីភាគច្រើនសម្រេចបានលទ្ធផល លើសពីការរំពឹងទុកនៃផែនការរបស់យើងក្នុងរយៈពេល១២ខែកន្លងមកនេះ។

យុវនារី-កុមារីចំនួន១០៤នាក់ បានទទួលការស្នាក់នៅពេញលេញនៅមណ្ឌលទំនុកចិត្ត ដោយរាប់បញ្ចូលទាំងសុវត្ថិភាពនៃការស្នាក់នៅ និងអាហារូបត្ថម្ភ ក្នុងនោះ៣៣នាក់ជាកុមារីចូលថ្មីក្នុងរយៈពេល១២ខែ។ យុវនារី-កុមារីចំនួន១២៧នាក់បានទទួលការថែទាំសុខភាព ១៤៤នាក់បានទទួលការពិគ្រោះយោបល់ចិត្តសង្គម ៦១នាក់បានទទួលជំនួយនីតិកម្ម (៣២នាក់ថ្មី)តាមប្រព័ន្ធតុលាការ ជនជាប់ចោទចំនួន៧២នាក់(២៩នាក់ថ្មី)ត្រូវបានចាប់ឃុំខ្លួននិង៣៥នាក់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារកម្រិតទោសទាបបំផុត៣ឆ្នាំនិង៦ខែ និងខ្ពស់បំផុត១២ឆ្នាំ។ សំណងរដ្ឋប្បវេណីទាបនិងខ្ពស់បំផុតពី១០ទៅ៤០លានរៀល ប៉ុន្តែជាទូទៅជនរងគ្រោះមិនដែលទទួលបានសំណងរដ្ឋប្បវេណីទេ។ យុវនារី-កុមារីចំនួន៧៤នាក់បានទទួលការបណ្តុះបណ្តាលជំនាញហាត់កម្ម និង៧២នាក់បានទទួលការបណ្តុះបណ្តាលអំពីសីលធម៌និងសុជីវធម៌។

យុវនារី-កុមារីចំនួន២២០នាក់ បានទទួលអាហារូបករណ៍ក្រោមឧត្តមសិក្សា ឧត្តមសិក្សាសាកលវិទ្យាល័យ និងជំនាញវិជ្ជាជីវៈ ដូចក្នុងតារាងបង្ហាញជូនខាងក្រោមនេះ៖

| ស្ថិតសង្ខេបកុមារីទទួលការថែទាំ&ឧបត្ថម្ភ | ២០២៤ | | ធ្នូ២០២៤ - មិថុនា២០២៥ | |
|---|---|---|---|---|
| | សរុប | សម្គាល់ | សរុប | សម្គាល់ |
| កុមារីទទួលការថែទាំក្នុងមណ្ឌល | ១០៤ | (៧១នាក់ចុងគ្រា២០២៣&៣៣នាក់ចូលថ្មី២០២៤) | ៧៣ | (៣១នាក់ចេញពីមណ្ឌល) |
| សិស្សអាហារូបករណ៍ក្រោមឧត្តមសិក្សា(ក្នុងម.ណ) | ១០២ | (៧៥នាក់ចុងគ្រា២០២៣ និង២៧នាក់ចូលរៀនថ្មី) | ៧៣ | (២៤នាក់អាហារូបករណ៍ក្រោមឧត្តមសិក្សា និង៥នាក់បោះបង់ការសិក្សា) |
| សិស្សអាហារូបករណ៍ជំនាញវិជ្ជាជីវៈ | ៧ | (៤នាក់ចុងគ្រា២០២៣ និង៣នាក់ចូលរៀនថ្មី) | ០ | (៥នាក់បញ្ចប់ការសិក្សាជំនាញ និង២នាក់បោះបង់) |
| សិស្សអាហារូបករណ៍ក្រោមឧត្តមសិក្សា(ក្រៅម.ណ) | ៩១ | (៦៦នាក់ចុងគ្រា២០២៣ និង២៥នាក់ចូលរៀនថ្មី) | ៨០ | (៤នាក់ជាប់មធ្យមសិក្សាទុតិយភូមិ និង៧នាក់បោះបង់) |
| និស្សិតអាហារូបករណ៍ឧត្តមសិក្សាសាកលវិទ្យាល័យ | ២០ | (១៦នាក់ចុងគ្រា២០២៣ និង៤នាក់ចូលរៀនថ្មី) | ១៧ | (២នាក់បានបញ្ចប់ការសិក្សា និង១នាក់បោះបង់) |
| សមាហរណកម្មជាមួយការងារ និងមុខរបរ | ១៥ | | ១៥ | ៥នាក់បានសមាហរណកម្មជាមួយមុខរបរ |
| សមាជិកបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ | ៦៦ | (៥៩នាក់ចុងគ្រា២០២៣ និង៧នាក់សមាជិកថ្មី) | ៦៦ | |
| ករណីសមាហរណកម្មស្ថិតក្រោមការតាមដានបន្ត | ២០២ | (១៧៩នាក់ចុងគ្រា២០២៣ និង២៣នាក់ថ្មី) | ២០២ | |
| សរុប | ៦០៧ | | ៥២៦ | |

# ករណីជោគជ័យ យុវនារីទទួលផលពីគម្រោងកម្មវិធី



**ហាង លក្ខណា** (PP-៣៤៦០) អាយុ១៩ឆ្នាំ (កើតឆ្នាំ ២០០៥) ជាអតីតកុមារីរងគ្រោះ ដោយការរំលោភបំពានប្រព្រឹត្ត ដោយឪពុកចុង កាលពីនាងមាន អាយុ១៤ឆ្នាំ។ ជនល្មើសត្រូវបាន ចាប់ខ្លួន និងផ្តន្ទាទោសជាប់ពន្ធ នាគារ៩ឆ្នាំ។ ដើម្បីសុវត្ថិភាព មន្ទីរ សង្គមកិច្ចខេត្តព្រៃវែងបានបញ្ជូននាងមកស្នាក់នៅក្នុងអង្គការ អាហ្វេស៊ីប នៅខែសីហា ឆ្នាំ២០១៩។

នាងបានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិនៅឆ្នាំ២០២៣ បានទទួលអាហារូបករណ៍បន្តឧត្តមសិក្សានៅសកលវិទ្យាល័យ។ ក្តីសុបិន្តនាងចង់ក្លាយជាចៅក្រម ព្រោះនាងចង់ជួយដល់ជនរងគ្រោះដទៃទៀត និងសហគមន៍ដែលនាងរស់នៅ។ មកដល់ពេលនេះ នាងទទួលការឧបត្ថម្ភគាំទ្រពីអង្គការអាហ្វេស៊ីបរយៈពេល៥ឆ្នាំ។ នាងកំពុងសិក្សាបរិញ្ញាបត្រច្បាប់ឆ្នាំទី៣ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

នាងសិក្សាពេលយប់ និងហាត់ការនៅកម្មវិធីអប់រំនិងបណ្តុះបណ្តាលអង្គការអាហ្វេស៊ីបកម្ពុជាពេលថ្ងៃ។ ការងារនាងគឺជួយគាំទ្រអតីតជនរងគ្រោះ ជាអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រោមមណ្ឌល ជួយមើលថែទាំប្អូនតូចៗ ធ្វើបច្ចុប្បន្នភាពឯកសាររបស់ក្មេងៗ និងការងារផ្សេងៗនៅក្នុងមណ្ឌលទុំឌី។



**ហាន ផល្លីន** (PP-៣៥៧៩) អាយុ១៦ឆ្នាំ (កើតឆ្នាំ ២០០៨) ជាអតីតកុមារីរងគ្រោះ ដោយការរំលោភបំពានប្រព្រឹត្ត ដោយបងថ្លៃ កាលនាងអាយុ១៥ ឆ្នាំ។ ដើម្បីសុវត្ថិភាព មន្ទីរសង្គម កិច្ចខេត្តរតនគិរីបានបញ្ជូននាង មកស្នាក់នៅក្នុងអង្គការអាហ្វេស៊ី ប នៅខែកញ្ញា ឆ្នាំ២០២៣។ ជន ល្មើសត្រូវបានចាប់ខ្លួននិងកាត់ទោសជាប់ ពន្ធនាគារ១០ឆ្នាំ។

ក្តីសុបិន្តនាងចង់ក្លាយជាជាងអ៊ុតសក់ នាងបានចូលរៀនជំនាញកែសម្ផស្សនៅហាងមួយនៅភ្នំពេញនៅខែធ្នូ ឆ្នាំ២០២៣ និងបានបញ្ចប់ការសិក្សាដោយជោគជ័យនៅខែសីហាឆ្នាំ២០២៤ បន្ទាប់មកបានសមាហរណកម្មនាងជាមួយការងារជំនាញកែសម្ផស្ស បានចំណូលផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់នាង។



**សុខស្រីពេជ** (PP-៣៥១៥) អាយុ២០ឆ្នាំ (កើតឆ្នាំ ២០០៤) ជាអតីតកុមារីរងគ្រោះ ដោយការរំលោភបំពានប្រព្រឹត្ត ដោយចោរប្លន់ កាលពីនាង មានអាយុ១៧ឆ្នាំ។ ជនល្មើស ត្រូវបានចាប់ខ្លួននិងកាត់ ទោសជាប់ពន្ធនាគារ១នាក់ ១៥ ឆ្នាំ ដោយតុលាការខេត្តកំពត។ ដើម្បី សុវត្ថិភាព មន្ទីរសង្គមកិច្ចខេត្តបានបញ្ជូននាងមកស្នាក់នៅក្នុង អង្គការអាហ្វេស៊ីប នៅខែសីហា ឆ្នាំ២០២១។

នាងបានទទួលអាហារូបករណ៍បន្តឧត្តមសិក្សា។ ក្តីសុបិន្តនាងចង់ធ្វើការក្នុងវិស័យពន្ធដារ។ មកដល់ពេលនេះ នាងទទួលការឧត្ថម្ភគាំទ្រពីអង្គការអាហ្វេស៊ីបរយៈពេល៣ឆ្នាំ។ នាងកំពុងសិក្សាបរិញ្ញាបត្រគណនេយ្យ និងហិរញ្ញវត្ថុឆ្នាំទី៤ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នាងសិក្សាពេលយប់ និងធ្វើការពេញម៉ោងនៅពេលថ្ងៃផ្នែកប្រតិបត្តិការនាំចូលនៅក្រុមហ៊ុនធ្វើនកស្តុភាកម្ពុជា ដោយបានទទួលចំណូលទៀងទាត់សម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់នាង។



**ស្រីភា** (PP-៣៥៩៣) អាយុ១៦ឆ្នាំ (កើតឆ្នាំ២០០៨) ជា អតីតកុមារីរងគ្រោះដោយការ រំលោភបំពានប្រព្រឹត្តដោយមេ ការសំណង់។ ដើម្បីសុវត្ថិភាព មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ បានបញ្ជូននាងមកស្នាក់នៅ ក្នុងអង្គការអាហ្វេស៊ីប នៅខែ កុម្ភៈ ឆ្នាំ២០២៤។ ជនល្មើសបាន រត់គេចខ្លួន ត្រូវតុលាការកាត់ទោសកំបាំងមុខជាប់ពន្ធនាគារ ១២ឆ្នាំ និងបានចេញដីកាឱ្យប៉ូលីសតាមចាប់ខ្លួន។ ក្តីសុបិន្ត នាងចង់ក្លាយជាជាងអ៊ុតសក់ នាងបានចូលរៀនជំនាញកែសម្ផស្សនៅហាងមួយនៅភ្នំពេញ នាខែធ្នូ ឆ្នាំ២០២៣ និងបានបញ្ចប់ការសិក្សាដោយជោគជ័យនៅខែមេសាឆ្នាំ២០២៤។ នាងបានចំណាយពេល៥ខែបញ្ចប់ការសិក្សាជំនាញនាងស្រឡាញ់ដោយជោគជ័យនៅខែកញ្ញា ឆ្នាំ២០២៤ បន្តហាត់ការមួយរយៈដើម្បីបង្កើនបទពិសោធ យើងនឹងសមាហរណកម្មនាងឆាប់ៗនេះ ជាមួយការងារជំនាញនាងបានសិក្សា ។

## កម្មវិធីស្នាក់នៅមណ្ឌល ទុំ ឌី

ជាកន្លែងព្យាបាលមួយ តាមរយៈការផ្តល់ជម្រកសុវត្ថិភាព អាហារ១ថ្ងៃ៣ពេល ការថែទាំ អាហារូបត្ថម្ភ ការពិនិត្យព្យាបាលសុខភាព ការពិគ្រោះចិត្តសង្គម និងជំនួយផ្នែកច្បាប់ ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍន៍សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត ដល់កុមារីរងគ្រោះដែលយើងធ្វើការជាមួយ។

## ហេតុអ្វីបានជាយើងធ្វើការនេះ?

មណ្ឌលទុំឌីជាដំណាក់កាលដំបូង ក្នុងការធ្វើឱ្យកុមារីរងគ្រោះ និងងាយរងគ្រោះមានស្ថេរភាព ផុតពីទុក្ខកង្វល់ដែលពួកគាត់បានជួបប្រទះ ជាទូទៅពួកគាត់អាចទទួលបានបរិយាកាសសុវត្ថិភាព ជួបជាមួយបុគ្គលិកថែទាំ គ្រូពេទ្យ ចិត្តសាស្រ្ត បុគ្គលិកគាំពារផ្នែកច្បាប់ សមាជិកបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ កសាងទំនុកចិត្ត និងទំនាក់ទំនង។

## តើធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ?

យើងបានផ្តល់ជម្រកសុវត្ថិភាព អាហារូបត្ថម្ភ សម្លៀកបំពាក់ និងគ្រឿងឧបភោគ-បរិភោគ ដល់កុមារីរងគ្រោះ និងងាយរងគ្រោះដោយអំពើហិង្សាផ្លូវភេទ ជួញដូរ រំលោភបំពាន ទាសភាព និងកេងប្រវ័ញ្ចផ្លូវភេទ នៅក្នុងមណ្ឌលទុំឌី។

## យើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថា យើងនឹងផ្តល់ការថែទាំគ្រប់ជ្រុងជ្រោយដល់យុវនារី-កុមារីចំនួន១០៦នាក់ នៅមណ្ឌលទុំឌី ក្នុងនោះ ៣០នាក់ជាកុមារីចូលថ្មីឆ្នាំ២០២៤ និង៧៦នាក់ទៀតនៅសល់ចុងគ្រាឆ្នាំ២០២៣។

## លទ្ធផលយើងសម្រេចបាន

យុវនារី-កុមារីចំនួន១០៤នាក់ បានទទួលការថែទាំគ្រប់ជ្រុងជ្រោយ ជម្រកសុវត្ថិភាព អាហារូបត្ថម្ភនៅមណ្ឌលទុំឌី។ ៣៣នាក់ចូលថ្មីឆ្នាំ២០២៤ និង៧១នាក់សល់ចុងគ្រាឆ្នាំ២០២៣ លទ្ធផលសម្រេចបានល្អចូលថ្មីលើសផែនការ។

## ប្រភពបញ្ជូនជនរងគ្រោះ

អាហ្វេស៊ីប បានកសាងបណ្តាញការងារជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(មន្ទីរ ស.អ.យ) អាជ្ញាធរមូលដ្ឋាននិងភាគីពាក់ព័ន្ធនៅតាមខេត្ត ជាប្រភពបញ្ជូនយុវនារី-កុមារីរងគ្រោះមកទទួលសេវាស្តារនៅមណ្ឌល។

## ស្ថិតយុវនារី-កុមារីចេញពីមណ្ឌល

- ១នាក់ បានស្តាររួច ទទួលអាហារូបករណ៍ជំនាញវិជ្ជាជីវៈ ស្នាក់នៅក្រៅមណ្ឌល។
- ៤នាក់ បញ្ជូនទៅគ្រួសារ ។
- ២នាក់ បានសមាហរណកម្មជាមួយការងារ(១) និងមុខរបរ(១)។
- ២៤នាក់ បានស្តាររួច សមាហរណកម្មជាមួយអាហារូបករណ៍ក្រោមឧត្តមសិក្សានៅក្រៅមណ្ឌលជាមួយគ្រួសារ
- ៧៣នាក់ បន្តទទួលការថែទាំពេញលេញ នៅក្នុងមណ្ឌលទុំ ឌី នៅចុងគ្រា ខែធ្នូ ឆ្នាំ២០២៤។

ដំណើរកំសាន្តទៅកាន់ខេត្តមណ្ឌលគិរី



**សម្តេច ហ៊ុន សែន** (អតីតនាយករដ្ឋមន្រ្តី) **ប្រធានព្រឹទ្ធសភា** និង **សម្តេច កត្តព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** បានអញ្ជើញទស្សនកិច្ច អាហ្សេស៊ីប កម្ពុជា។




## កម្មវិធីថែទាំសុខភាព

ជនរងគ្រោះដោយការជួញដូរ រំលោភសេពសន្ថវៈ រំលោភបំពានផ្លូវភេទ ឬការកេងប្រវ័ញ្ចផ្លូវភេទ តែងតែជាប់នូវស្លាកស្នាមវិប្បដិសារី និងការមាក់ងាយពីមជ្ឈដ្ឋានជុំវិញ ដែលជាកត្តាធ្វើឱ្យប៉ះបាល់ដល់ការអភិវឌ្ឍផ្លូវកាយ និងផ្លូវចិត្ត។ កុមារីទទួលបានការពិនិត្យ និងវាយតម្លៃសុខភាពទូទៅ នៅពេលពួកគាត់មកដល់មណ្ឌលភ្លាម និងផ្តល់ការពិនិត្យ ព្យាបាលបន្ត តាមតម្រូវការជាក់ស្តែងពីវេជ្ជបណ្ឌិតរបស់យើង។

## អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថា យើងនឹងផ្តល់ការថែទាំសុខភាព១០០%ដល់កុមារីចូលថ្មីចំនួន៣០នាក់ នៅមណ្ឌលទុំឌី និងផ្តល់ការពិនិត្យ ព្យាបាលបន្ត ដល់កុមារីចំនួន៨០នាក់ តាមតម្រូវការជាក់ស្តែងរបស់ករណីនីមួយៗ។

## លទ្ធផលយើងសម្រេចបាន

៩៧%នៃកុមារីចូលថ្មីចំនួន៣៣នាក់(៣២/៣៣) នៅមណ្ឌលទុំឌីបានទទួលការពិនិត្យ វាយតម្លៃ និងព្យាបាលសុខភាពលើរោគសញ្ញាសំខាន់ៗ ដូចជា បាក់តេរីទ្វារមាស ផ្សិតទ្វារមាស រលាកទ្វារមាសបង្កដោយមេរោគ និងរលាកបំពង់បង្ហូរទឹកនោម។ កុមារីចំនួន១២៧នាក់បានទទួលការពិនិត្យ និងព្យាបាលបន្តចំនួន១៣៣០ដង តាមតម្រូវការជាក់ស្តែង លើរោគសញ្ញារាគ ជំងឺកង្វះគ្រាប់ឈាមក្រហម ជំងឺអ៊ុតស្វាយ គ្រុនផ្តាសាយ និងរលាកបំពង់ក នៅក្នុងឆ្នាំ២០២៤។ លទ្ធផលសម្រេចបានល្អ លើសពីផែនការរំពឹងទុក។

- ១០៣នាក់ បានចាក់វ៉ាក់សាំងជាតិ១១មុខ បង្ការស្អូច កញ្ជ្រឹល រលាកស្រោមខួរក្បាល ផ្តាសាយ និងថ្លើមប្រភេទបេ។
- ១២៧នាក់ បានចាក់វ៉ាក់សាំងបង្ការជំងឺផ្តាសាយ ក្នុងនោះយុវនារី-កុមារី៩៥ និងបុគ្គលិក៣២នាក់។
- ២២នាក់ បានពិនិត្យ ព្យាបាលមាត់ធ្មេញ នៅអង្គការគ្រួសារពិភពលោកកម្ពុជា។ ៤នាក់បានព្យាបាលកម្រិតធ្ងន់។

- ៩៧នាក់ បានពិនិត្យ ព្យាបាល ថែទាំភ្នែក ត្រចៀក ច្រមុះ និងបំពង់ក (EENT) នៅមជ្ឈមណ្ឌលវះកាត់កុមារ។ ១៦នាក់ បានព្យាបាលកម្រិតដោយត្រូវពាក់វ៉ែនតាម៉្យោប។
- ៩២នាក់ បានធ្វើតេស្តឈាម CBC glycaemia និង Ag-Anti-HBS។ ៨០នាក់ បានធ្វើតេស្តហ៊ីវ ដោយស្ម័គ្រចិត្ត។
- ៤ករណី បានទទួលថ្នាំព្យាបាលជំងឺគំរាមកំហែងអាយុជីវិតធ្ងន់ធ្ងរ សង្គ្រោះបន្ទាន់និងសម្រាកនៅមន្ទីរពេទ្យ។ កុមារីចំនួន១នាក់ បានទទួលថ្នាំព្យាបាលជំងឺថ្លើមប្រភេទ ចតអេកូ និងធ្វើPCR។
- ១៥នាក់ បានទទួលសោភ័ណ្ឌសម្រស់ សម្ភារអនាម័យពិសេស ពេលគាត់ពេញវ័យ (ពេលមករដូវ)
- ១០៣នាក់ បានអប់រំសុខភាពបឋម ស្តីពីសុវត្ថិភាពចំណីអាហារ គឺមី៣ប្រភេទប្រើក្នុងចំណីអាហារនិងផលប៉ះពាល់ជំងឺអ៊ុតស្វាយ រាគ ការឡើងកំដៅ ហានិភ័យការប្រើប្រាស់អាលុយមីញ៉ូមវិចខ្ចប់ចំណីអាហារ និងជំងឺគ្រុនពោះវៀន។



ការថែទាំភ្នែក



ចាក់វ៉ាក់សាំងបង្ការផ្តាសាយ




វគ្គបណ្តុះបណ្តាលសុខភាពបឋម

## កម្មវិធីចិត្តសាស្ត្រ

យើងដឹងហើយថា ឥទ្ធិពលនៃផលប៉ះពាល់ផ្នែកសុខភាពផ្លូវចិត្ត គឺការបាក់ទឹកចិត្ត និងការផ្តាច់ទំនាក់ទំនង ដូច្នេះកម្មវិធីស្តារនីតិសម្បទា យើងផ្តោតលើការលើកទឹកចិត្ត និងការបង្កើតទំនាក់ទំនងថ្មីៗ ដល់កុមារីដែលយើងធ្វើជាមួយទាំងនៅក្នុងមណ្ឌល និងនៅតាមសហគមន៍។ ពេលពួកគាត់មកដល់មណ្ឌលភ្លាម បានទទួលការវាយតម្លៃសុខភាពផ្លូវចិត្ត ការព្យាបាលបន្ទាន់ និងការតាមដានសុខភាពជាបន្តបន្ទាប់តាមតម្រូវការជាក់ស្តែងពីបុគ្គលិកចិត្តវិទ្យារបស់យើង។

## អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថា១០០%នៃកុមារីរងគ្រោះចូលថ្មី៣០នាក់ នឹងទទួលបានការវាយតម្លៃសុខភាពផ្លូវចិត្ត ពេលពួកគាត់មកមណ្ឌលទុំឌី និងកុមារីចំនួន៦៦នាក់ នឹងទទួលបានការតាមដាន និងព្យាបាលសុខភាពផ្លូវចិត្តតាមតម្រូវការជាក់ស្តែង។

## លទ្ធផលយើងសម្រេចបាន

១០០%នៃចំនួនកុមារីរងគ្រោះចូលថ្មី៣៣នាក់ នៅមណ្ឌលទុំឌី បានទទួលការវាយតម្លៃសុខភាពផ្លូវចិត្តទូទៅ ដែលមានរោគសញ្ញាព្រួយបារម្ភ នឹកផ្ទះ ខ្លាច សុបិន្តអាក្រក់ និងការថប់បារម្ភ ។ កុមារីចំនួន១៤៤នាក់ បានទទួលការតាមដាននិង

ព្យាបាលសុខភាពផ្លូវចិត្តចំនួន៣៩៧ដង តាមតម្រូវការជាក់ស្តែង លើរោគសញ្ញា ព្រួយបារម្ភ មិនសប្បាយចិត្ត អារម្មណ៍ធ្លាក់ចុះ និងសុបិន្តអាក្រក់។ លទ្ធផលសម្រេចបានល្អ លើសផែនការរំពឹងទុក។

- ៧៧នាក់ បានព្យាបាលសុខភាពផ្លូវចិត្ត តាមបែបសិល្បៈចំនួន១៨វគ្គ ដូចជាគូររូប និងផាត់ពណ៌ផ្សេងៗ។
- ៨១នាក់ បានទទួលការបណ្តុះបណ្តាល ការជួយខ្លួនឯងបានចំនួន២៣វគ្គ អំពីប្រធានបទផ្សេងៗដូចជា ការការថប់បារម្ភ ឆ្លុះបញ្ចាំងខ្លួនឯង ការលើកទឹកចិត្តខ្លួនឯង ការគ្រប់គ្រងកំហឹង ការជឿជាក់លើខ្លួនឯង នីតិវិធីតុលាការ ស្វ័យថែទាំ ការពង្រឹងធនធាន និងការប្រឈមនៅតុលាការ និងគ្រប់គ្រងភាពតានតឹង។
- ១៩នាក់ បានបណ្តុះបណ្តាល សុខភាពផ្លូវចិត្តបឋម និងការអប់រំបង្ការ៣វគ្គ អំពីប្រធានបទអប់រំចិត្តសង្គមផ្សេងៗ។
- ៩៥នាក់ បានហ្វឹកហ្វឺន និងអនុវត្តយោគៈជាប្រចាំនៅចុងសប្តាហ៍បាន៥៩វគ្គ នៅមណ្ឌលទុំឌី។
- ៦នាក់ និង១គ្រួសារ បានពិគ្រោះយោបល់មុន អំឡុង និងក្រោយពេលចូលបំភ្លឺ និងសវនការជម្រះក្តីនៅតុលាការ។
- ៨នាក់ បានទទួលការពិគ្រោះយោបល់ចិត្តសង្គមនៅមុន អំឡុង និងក្រោយពេលទទួលចូលមណ្ឌលទុំឌី ។
- ៩៩នាក់ បានហ្វឹកហ្វឺន និងអនុវត្តសមាធិជាប្រចាំបាន៤៧វគ្គ នៅមណ្ឌលទុំឌី ជាពិសេសថ្ងៃសីល។

សកម្មភាពបែបសិល្បៈក្នុងការកសាងភាពជឿជាក់ឡើងវិញ



សកម្មភាពការជួយគ្នាជាក្រុម



ការស្តារទំនុកចិត្តផ្ទាល់ខ្លួន



## កម្មវិធីគាំពារនីតិកម្ម

បុគ្គលិកផ្នែកនីតិកម្មធានាថាគ្រប់ជនរងគ្រោះទាំងអស់ ដែលយើងធ្វើការជាមួយពាក់ព័ន្ធនីតិវិធីច្បាប់ យើងផ្តល់ជំនួយផ្នែកច្បាប់ និងជាតំណាងតាមនីតិវិធីច្បាប់ ដោយធ្វើការសហការជិតស្និតជាមួយបណ្តាអង្គការ-ស្ថាប័នដៃគូផ្សេងៗ រៀបចំឯកសារផ្នែកច្បាប់ ដើម្បីឱ្យជនសង្ស័យប្រឈមមុខចំពោះយុត្តិធម៌ និងធានាឱ្យបានថាជនរងគ្រោះទទួលបានការយកចិត្តទុកដាក់ដោយស្មើភាពចំពោះមុខច្បាប់ ។

## អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារីចំនួន៦០នាក់ ដែលពាក់ព័ន្ធនីតិវិធីច្បាប់ នឹងទទួលបានជំនួយផ្នែកច្បាប់ តាមនីតិវិធី។ ក្នុងនោះមាន៣០នាក់ ជាករណីចុងគ្រាឆ្នាំ២០២៣ និង៣០នាក់ទៀត ជាករណីថ្មីពាក់ព័ន្ធច្បាប់ក្នុងឆ្នាំ២០២៤។

## លទ្ធផលយើងសម្រេចបាន

៦១នាក់ បានទទួលជំនួយផ្នែកច្បាប់តាមនីតិវិធី។ ក្នុងនោះ២៩នាក់ ជាករណីចុងគ្រាឆ្នាំ២០២៣ និង៣២នាក់ ជាករណីថ្មីពាក់ព័ន្ធនីតិវិធីច្បាប់កឆ្នាំ២០២៤ លទ្ធផលសម្រេចបានល្អលើសផែនការ។

- ៧២នាក់ ជាជនសង្ស័យត្រូវបានចាប់ឃុំខ្លួនឱ្យទទួលខុសត្រូវចំពោះមុខច្បាប់។ ក្នុងនោះ៤៣នាក់ ជាករណីចុងគ្រាឆ្នាំ២០២៣ និង២៩នាក់ជាករណីថ្មីត្រូវប៉ូលីសចាប់ឃុំខ្លួនក្នុងឆ្នាំ២០២៤។
- ២៧នាក់ ជាមេធាវីយើងបានស្នើសុំពីបណ្តាអង្គការ-ស្ថាប័នដៃគូ និងក្រុមមេធាវីស្ម័គ្រចិត្ត**សម្តេចតេជោ ហ៊ុន សែន** ដើម្បីការពារក្តី និងជាតំណាងជនរងគ្រោះតាមនីតិវិធីនៅតុលាការ។
- ៣២នាក់ ជាកុមារីរងគ្រោះបានធ្វើកោសល្យវិច្ឆ័យ ជាភស្តុតាងដាក់បន្ទុកជនល្មើស មុខច្បាប់នៅតុលាការ។
- ២៣នាក់ បានចូលឆ្លើយបំភ្លឺ២៧ដង និង២៦នាក់បានចូលរួមសវនាការជម្រះក្តីចំនួន២៩ដង នៅតុលាការ( ករណីខ្លះលើសពី១ដង )។ ជនល្មើសចំនួន៣៥នាក់ ត្រូវបានតុលាការផ្តន្ទាទោសឱ្យជាប់ព័ន្ធនាគារ ពី៣ឆ្នាំ៦ខែ-១២ឆ្នាំ។ បង្គាប់សំណងរដ្ឋប្បវេណីពី១០-៤០លានរៀល ប៉ុន្តែជនរងគ្រោះមិនដែលទទួលបានទេ។
- ៥១នាក់ បានទទួលការតាមដានជាមួយមេធាវី អំពីវឌ្ឍនភាពលើករណីពាក់ព័ន្ធនីតិវិធីច្បាប់បានចំនួន៨៤៩ដង ភាគច្រើនធ្វើការតាមដានតាមទូរស័ព្ទ។ បានប្រជុំដោយផ្ទាល់៣៣ដង និងទាក់ទងតាមទូរស័ព្ទ២៨៧ដង ជាមួយមន្ត្រីសង្គមកិច្ច និងអាជ្ញាធរមូលដ្ឋាន អំពីការចុះទទួលកុមារីរងគ្រោះថ្មីចូលមណ្ឌល។

នីតិវិធីប្រគល់-ទទួលកុមាររងគ្រោះ



កុមារចូលសវនាការសាលាដំបូង



កុមារចូលសវនាការសាលាឧទ្ធរណ៍



## កម្មវិធីអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ

យុវនារី-កុមារីបានទទួលការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជាក់លាក់មួយ ស្ថិតក្នុងបរិស្ថានសុវត្ថិភាព នៅតាមបណ្តាសាលារដ្ឋ និងសាលាវិជ្ជាជីវៈពិតប្រាកដសម្រាប់ជំនាញវិជ្ជាជីវៈ។ យើងបានដាក់ផែនការយុវនារី-កុមារីចំនួន២០៥នាក់ នឹងទទួលបានការឧបត្ថម្ភការសិក្សាអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ តាមប្រភេទនីមួយៗដូចខាងក្រោម។ ការអប់រំយើងផ្តល់ឱ្យពីថ្នាក់មត្តេយ្យ ដល់ឧត្តមសិក្សានៅសាកលវិទ្យាល័យៈ

- ៩៥នាក់ នឹងទទួលបានអាហារូបករណ៍ ក្រោមឧត្តមសិក្សា ស្នាក់នៅក្នុងមណ្ឌលទំនុំឌី។
- ៨៥នាក់ នឹងទទួលបានអាហារូបករណ៍ ក្រោមឧត្តមសិក្សា ស្នាក់នៅក្រៅមណ្ឌលជាមួយគ្រួសារ។
- ១៧នាក់ នឹងទទួលបានអាហារូបករណ៍ឧត្តមសិក្សាសាកលវិទ្យាល័យ។
- ៨នាក់ នឹងទទួលបានអាហារូបករណ៍ជំនាញវិជ្ជាជីវៈ។

### ហេតុអ្វីបានជាយើងធ្វើការនេះ?

ទិសដៅចម្បងរបស់យើងគឺធ្វើឱ្យអ្នកទទួលផល សម្រេចបាននូវស្វ័យភាព ពិសេសគឺឯករាជ្យភាពហិរញ្ញវត្ថុ តាមរយៈការផ្តល់ឱកាសឱ្យពួកគាត់មានការងារធ្វើ ឬបង្កើតមុខរបរផ្ទាល់ខ្លួនក្រោយពេលបញ្ចប់ការសិក្សា។

### តើធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ?

យុវនារី-កុមារីចំនួន២២០នាក់ បានទទួលអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្នុងមណ្ឌល ស្នាក់នៅក្រៅមណ្ឌលជាមួយក្រុមគ្រួសារពួកគាត់ បន្ទាប់ពីបានស្តារ និងសមាហរណកម្មទៅតាមមូលដ្ឋាន នៅសហគមន៍វិញ នៅទូទាំងកម្ពុជា អាហារូបករណ៍ឧត្តមសិក្សាសាកលវិទ្យាល័យ និងអាហារូបករណ៍ជំនាញវិជ្ជាជីវៈ។ លទ្ធផលសម្រេចបានល្អលើសផែនការ។ លទ្ធផលបានបង្ហាញនៅតារាងរបាយការណ៍សង្ខេបខាងលើ។

- ១១នាក់ អាហារូបករណ៍ក្រោមឧត្តមសិក្សា បានប្រឡងជាប់មធ្យមសិក្សាបឋមភូមិស្ថាពរ។
- ៦នាក់(២នាក់ស្វ័យរិន) អាហារូបក្រោមឧត្តមសិក្សា បានប្រឡងមធ្យមសិក្សាទុតិយភូមិ(៤នាក់ជាប់)។
- ៧នាក់ អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល បានបោះបង់ការសិក្សា។ យើងបានផ្តាច់អាហារូបករណ៍ឧត្តមសិក្សាសាកលវិទ្យាល័យ១នាក់ ព្រោះបានបំពានកិច្ចព្រមព្រៀងអាហារូបករណ៍ និងក្រមសីលធម៌។

## អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្នុងមណ្ឌល

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

ផែនការយើង កុមារីចំនួន៩៥នាក់ នឹងទទួលបានអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្នុងមណ្ឌលទំនុំឌី។ ក្នុងនោះ ៧០នាក់ សល់ចុងគ្រាឆ្នាំ២០២៣ និង២៥នាក់ ចូលរៀនថ្មីឆ្នាំ២០២៤។

## លទ្ធផលយើងសម្រេចបាន

កុមារី១០២នាក់ បានទទួលអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្នុងមណ្ឌលទុំឌី។ ក្នុងនោះ៧៥នាក់ សល់ចុងគ្រាឆ្នាំ២០២៣ និង២៧នាក់ ចូលរៀនថ្មីឆ្នាំ២០២៤ ទទួលបានឯកសណ្ឋានសិស្ស សម្ភារសិក្សា ប្រាក់ប្រចាំថ្ងៃសម្រាប់អាហារសម្រន់ មធ្យោបាយដឹកជញ្ជូនទៅ-មកសាលា ការចុះឈ្មោះចូលរៀន ការតាមដាន និងការឧបត្ថម្ភផ្សេងៗតាមតម្រូវការជាក់ស្តែង។ ស្ថិតិបញ្ជូនចេញពីមណ្ឌល៖

- ៥នាក់ បានសមាហរណកម្មទៅគ្រួសារវិញ ដោយមិនទាន់បានឧបត្ថម្ភនៅឡើយ។
- ២៤នាក់ បានសមាហរណកម្មទៅគ្រួសារ ដោយឧបត្ថម្ភអាហារូបករណ៍ក្រោមឧត្តមសិក្សា ស្នាក់នៅក្រៅមណ្ឌល
- ៧៣នាក់ កំពុងបន្តអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្នុងមណ្ឌល។

- បានបង្កើតក្រុមមិត្តសិក្សាចំនួន៦ក្រុម ដោយជ្រើសរើសសិស្សពូកែនៅកម្រិតបឋម និងវិទ្យាល័យ ជួយបង្រៀនសិស្សរៀនខ្សោយ។ ៣ក្រុម បង្រៀនសិស្សបឋម និង៣ក្រុមទៀត បង្រៀនសិស្សកម្រិតវិទ្យាល័យ។

- សិស្សអាហារូបករណ៍ក្រោមឧត្តមសិក្សា ស្នាក់នៅក្នុងមណ្ឌលចំនួន២៧នាក់បានរៀនគួរបន្ថែម ក្នុងនោះសិស្សថ្នាក់ទី៦( ៨នាក់ ) ថ្នាក់ទី៩( ១៦នាក់ ) និង១២( ៣នាក់ )។

- ៥២នាក់ បានទទួលការជួយសម្របសម្រួលឯកសារចុះឈ្មោះចូលរៀន នៅតាមសាលាសារដ្ឋ។ ក្នុងនោះ៣២នាក់ ជាអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្នុងមណ្ឌល និង២០នាក់ ជាសិស្សអាហារូបករណ៍ស្នាក់នៅក្រៅមណ្ឌល ដែលបានសមាហរណកម្មទៅគ្រួសារវិញ បន្តការសិក្សានៅមូលដ្ឋានតាមសហគមន៍។

- បានប្រជុំប្រចាំខែចំនួន១០ដង ជាមួយសិស្សអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្នុងមណ្ឌល ដើម្បីពិនិត្យតាមដាន លើវឌ្ឍនៈភាព នៃការសិក្សារបស់ពួកគាត់ នៅតាមសាលារដ្ឋ។

- បានផ្តល់រង្វាន់លើកទឹកចិត្តដល់សិស្សពូកែចំនួន៤នាក់ បានខិតខំសិក្សាទទួលនិទ្ទេសល្អពីលេខ១-៣។

ចែកឯកសណ្ឋានសិស្ស និងសម្ភារសិក្សា ឆ្នាំសិក្សា២០២៤-២០២៥



ការដឹកជញ្ជូនក្មេងៗទៅសាលា





# អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល

## អ្វីយើងបាននិយាយថាយើងនឹងធ្វើ

កុមារីចំនួន**៨៣**នាក់ នឹងទទួលបានអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល ជាមួយគ្រួសារបន្ទាប់ពីពួកគាត់បានស្តារនីតិសម្បទា។ ៣៨នាក់ ស្ថិតិចុងគ្រាឆ្នាំ២០២៣ និង១៥នាក់ ចូលរៀនថ្មីឆ្នាំ២០២៤។

## លទ្ធផលយើងសម្រេចបាន

កុមារី**៩១**នាក់ បានទទួលអាហារូបករណ៍ក្រោមឧត្តមសិក្សា ស្នាក់នៅក្រៅមណ្ឌល ជាមួយគ្រួសារនៅតាមមូលដ្ឋាន សហគមន៍បន្ទាប់ពីពួកគាត់បានស្តារ ក្នុងនោះ៦៦នាក់ ស្ថិតិចុងគ្រាឆ្នាំ២០២៣ និង២៥នាក់ ចូលរៀនថ្មីឆ្នាំ២០២៤។ ពួកគាត់បានទទួលឯកសណ្ឋានសិស្ស សម្ភារសិក្សា កង់សម្រាប់ជាមធ្យោបាយធ្វើដំណើរទៅសាលារៀន ការចុះឈ្មោះចូលរៀន ការតាមដានបន្ត និងការឧបត្ថម្ភផ្សេងៗ តាមតម្រូវការជាក់ស្តែង។ ស្ថិតិចេញពីកម្មវិធី៖

- ៤នាក់ អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល បានប្រឡងមធ្យមសិក្សាទុតិយភូមិ បន្តអាហារូបករណ៍ឧត្តមសិក្សា នៅសាកលវិទ្យាល័យ។
- ៧នាក់ អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល បានបោះបង់ការសិក្សា។ ក្នុងនោះអង្គការបានជួយឱ្យពួកគាត់បង្កើតមុខរបរខ្នាតតូច៥នាក់ ដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារ និង២នាក់ ប្តូររៀនជំនាញវិជ្ជាជីវៈ។
- ៨០នាក់ ស្ថិតិចុងគ្រាអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌលជាមួយគ្រួសារ កំពុងបន្តការសិក្សា។
- ២២នាក់ អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល បានទទួលការឧបត្ថម្ភកង់ម្នាក់១គ្រឿង។
- ១១នាក់ អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល បានរៀនគួរបន្ថែម ក្នុងនោះថ្នាក់ទី៩ ៧នាក់ និងថ្នាក់ទី១២ ៤នាក់ ដោយប្រើប្រាស់ប្រាក់ឧបត្ថម្ភប្រចាំខែរបស់សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។
- ៨២នាក់ អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅ បានទទួលការតាមដានបន្តចំនួន២៨៨ដង ។

យើងចែកឯកសណ្ឋានសិស្ស សម្ភារសិក្សា និងកង់ ដល់អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល ជាមួយគ្រួសារនៅមូលដ្ឋាន តាមសហគមន៍ សម្រាប់ឆ្នាំសិក្សាថ្មី២០២៤-២០២៥





## អាហារូបករណ៍ឧត្តមសិក្សាសាកលវិទ្យាល័យ

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាយុវនារី**១៧**នាក់ នឹងទទួលអាហារូបករណ៍ឧត្តមសិក្សា សិក្សានៅតាមបណ្តាសាកលវិទ្យាល័យ។ ក្នុងនោះចុងគ្រាឆ្នាំ២០២៣ ចំនួន១២នាក់ និងនិស្សិតថ្មី៥នាក់ ឆ្នាំ២០២៤។

### លទ្ធផលយើងសម្រេចបាន

យុវនារីចំនួន**២០**នាក់ បានទទួលអាហារូបករណ៍ឧត្តមសិក្សាសាកលវិទ្យាល័យ បានសិក្សានៅតាមបណ្តាសាកលវិទ្យាល័យផ្សេងៗនៅក្នុងរាជធានីភ្នំពេញ។ ក្នុងនោះ១៦ស្ថិតិចុងគ្រាឆ្នាំ២០២៣ និង៤នាក់ទៀតជានិស្សិតថ្មីឆ្នាំ២០២៤។ លទ្ធផលសម្រេចបានច្រើនជាងផែនការ ដោយសារនិស្សិត៤នាក់ ក្នុងចំណោម២០នាក់ យើងគម្រោងនឹងឱ្យពួកគាត់ចូលរៀននៅដើមឆ្នាំ២០២៥ តែពួកគាត់បានចូលរៀនមុនផែនការនៅចុងឆ្នាំ២០២៤ បន្ទាប់ពីពួកគាត់បានប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិថ្នាក់ទី១២រួច។

និស្សិតអាហារូបករណ៍ទាំងអស់ ដែលកំពុងសិក្សាឆ្នាំទី១ និង២ត្រូវស្នាក់នៅក្នុងមណ្ឌល ហើយចាប់ពីឆ្នាំទី៣ឡើងទៅត្រូវចេញទៅស្នាក់នៅខាងក្រៅ ដើម្បីចាប់ផ្តើមរស់នៅដោយស្វ័យឯករាជ្យភាព និងអាចចាប់ផ្តើមស្វែងរកការហាត់ការឬការងារក្រៅម៉ោង ដើម្បីឱ្យមានបទពិសោធន៍ការងារ និងរកប្រាក់ចំណូលបានខ្លះ។ ក្នុងអំឡុងពេលពួកគាត់ស្នាក់នៅក្នុងមណ្ឌល ពួកគាត់ចាប់ផ្តើមផ្តល់ឱ្យសង្គមវិញខ្លះៗ តាមរយៈការជួយការងារក្នុងមណ្ឌលនៅក្រៅម៉ោងសិក្សារបស់ពួកគាត់។ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា លោកបានផ្តល់ការឧបត្ថម្ភអាហារូបករណ៍បង់ថ្លៃសាលាដល់និស្សិតឧត្តមសិក្សាទាំងអស់ រីឯអង្គការ អាហ្វេស៊ីប កម្ពុជា យើងបានផ្តល់ការឧបត្ថម្ភការរស់នៅប្រចាំខែ ការសិក្សាភាសាអង់គ្លេស ការសិក្សាកុំព្យូទ័រ កុំព្យូទ័រយួដៃ១នាក់១គ្រឿងសម្រាប់ជំនួយដល់ការសិក្សា ការថែទាំសុខភាព សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន ។ ស្ថិតិចេញពីកម្មវិធី៖

- ២នាក់ បានបញ្ចប់ការសិក្សាដោយជោគជ័យ បរិញ្ញាបត្រនីតិសាស្ត្រ មានការងារធ្វើដោយប្រើប្រាស់ជំនាញបានសិក្សា។
- ១នាក់ ត្រូវបានផ្តាច់អាហារូបករណ៍ មូលហេតុរំលោភបំពានកិច្ចព្រមព្រៀងអាហារូបករណ៍ និងក្រមសីលធម៌។
- ១៧នាក់ កំពុងបន្តអាហារូបករណ៍ឧត្តមសិក្សាសាកលវិទ្យាល័យ នៅទីក្រុងភ្នំពេញ។

- ៤នាក់ និស្សិតឧត្តមសិក្សាថ្មី បានទទួលកុំព្យូទ័រយួដៃ១នាក់១គ្រឿង ជាជំនួយដល់ការសិក្សារៀនសូត្រពួកគាត់។
- ២០នាក់ និស្សិតអាហារូបករណ៍ឧត្តមសិក្សា បានទទួលការតាមដានបន្តចំនួន១៧២ដង ពីក្រុមការងារកម្មវិធីអប់រំនិងបណ្តុះបណ្តាល លើវឌ្ឍនភាពនៃការសិក្សា បញ្ហាសុខភាព និងបញ្ហាប្រឈមផ្សេងៗ។
- ពួកគាត់បានទទួលវគ្គបណ្តុះបណ្តាលខ្លី ស្តីអំពីមូលដ្ឋានស្វ័យគ្រប់គ្រងហិរញ្ញវត្ថុ។ វគ្គបណ្តុះបណ្តាលនេះជួយពួកគាត់ឱ្យចេះគ្រប់គ្រងនិងធ្វើផែនការហិរញ្ញវត្ថុប្រចាំខែផ្ទាល់ខ្លួនឱ្យបានត្រឹមត្រូវច្បាស់លាស់។ ចំណេះដឹងមូលដ្ឋានគ្រឹះនេះអាចជួយពួកគាត់ឱ្យសម្រេចបានគោលដៅឯករាជ្យភាពហិរញ្ញវត្ថុនាពេលអនាគត។

- ពួកគាត់បានទទួលការសិក្សាភាសាអង់គ្លេសតាមអនឡាញយ៉ាងទៀងទាត់ ពីគ្រូអង់គ្លេសភាសាកំណើតអង់គ្លេសជីល្ល និងលិន្ដា ដែលរស់នៅប្រទេសអង់គ្លេស។ ការសិក្សាភាសាអង់គ្លេសជាមួយគ្រូដើមកំណើតនិយាយភាសាអង់គ្លេសជួយឱ្យពួកគាត់អនុវត្តភាសាអង់គ្លេសដោយភាពជឿជាក់។

បុគ្គលិកយើងនាំនិស្សិតអាហារូបករណ៍ឧត្តមសិក្សាថ្មី ចុះសិក្សាព័ត៌មានស្វែងយល់អំពីជំនាញមុខវិជ្ជាដែលពួកគាត់ស្រឡាញ់ នៅតាមសាកលវិទ្យាល័យនានា សម្រាប់ការចុះឈ្មោះចូលសិក្សាតាមសាកលវិទ្យាល័យ។






## អាហារូបករណ៍ជំនាញវិជ្ជាជីវៈ

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាយុវនារី៨នាក់ នឹងទទួលអាហារូបករណ៍ជំនាញវិជ្ជាជីវៈ។

### លទ្ធផលយើងសម្រេចបាន

យុវនារីចំនួន៧នាក់ បានទទួលអាហារូបករណ៍ជំនាញវិជ្ជាជីវៈ។ ស្ថិតិចុងគ្រាឆ្នាំ២០២៣ចំនួន៤នាក់ និងអាហារូបករណ៍ថ្មីចំនួន៣នាក់ ឆ្នាំ២០២៤។ យើងផ្តល់ការឧបត្ថម្ភអាហារូបករណ៍ជំនាញវិជ្ជាជីវៈដល់យុវនារីដែលមិនអាចសិក្សាចំណេះដឹងទូទៅ នៅសាលារដ្ឋបាន ដោយមូលហេតុផ្សេងៗ។ យើងមិនមានផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅក្នុងមណ្ឌលទេ ប៉ុន្តែយើងបញ្ជូនពួកគាត់ ទៅសិក្សាជំនាញពួកគាត់ពេញចិត្ត នៅតាមសាលាវិជ្ជាជីវៈនៅខាងក្រៅមណ្ឌល។ យើងឧបត្ថម្ភថ្លៃសិក្សា សម្ភារសិក្សា ថ្លៃការរស់នៅប្រចាំខែ ការថែទាំសុខភាព ការពិគ្រោះយោបល់ និងការតម្រង់ទិសជួយដល់ពួកគាត់។

- ៥នាក់ អាហារូបករណ៍ជំនាញវិជ្ជាជីវៈ បានបញ្ចប់ការសិក្សាជំនាញវិជ្ជាជីវៈដោយជោគជ័យ។
- ២នាក់ អាហារូបករណ៍ជំនាញវិជ្ជាជីវៈ បានបោះបង់ការសិក្សាដោយមូលហេតុផ្សេងៗ។
- យើងបានចុះតាមដានការសិក្សារៀនសូត្រសិស្សអាហារូបករណ៍ជំនាញវិជ្ជាជីវៈទាំងអស់បានចំនួន៤៤ដង។

សកម្មភាពសិក្សាជំនាញកែសម្ផស្ស



ការបញ្ចប់ការសិក្សាជំនាញកែសម្ផស្សដោយជោគជ័យ




## ការបង្រៀនភាសាអង់គ្លេស

ភាសាអង់គ្លេស ជាភាសាអន្តរជាតិមួយ ដែលត្រូវបានប្រើប្រាស់ជាប្រចាំថ្ងៃនៅជុំវិញពិភពលោក វាជាភាសាស្តង់ដារមួយដែលត្រូវបានប្រើប្រាស់ក្នុងវិស័យផ្សេងៗជាច្រើន ដូចជាការប្រាស្រ័យទាក់ទងអន្តរជាតិ កូដកុំព្យូទ័រ និងក្នុងវិស័យអប់រំជាន់ខ្ពស់ជាដើម។ កម្ពុជា ក៏ជាប្រទេសមួយ ដែលប្រើប្រាស់ភាសាអង់គ្លេសប្រចាំថ្ងៃសម្រាប់ការទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ការសិក្សា និងការងារតាមវិស័យផ្សេងៗ។ យើងផ្តល់ការបង្រៀនភាសាអង់គ្លេសដល់យុវនារី-កុមារីដែលយើងធ្វើការជាមួយ ដើម្បីជាប្រយោជន៍ដល់ពួកគាត់ យកវាទៅប្រើប្រាស់សម្រាប់ការងារប្រចាំថ្ងៃពេលពួកគាត់ធំឡើង។

## អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារី៦០នាក់ នឹងទទួលបានការសិក្សាភាសាអង់គ្លេស។

## លទ្ធផលយើងសម្រេចបាន

កុមារីចំនួន៨៥នាក់ បានសិក្សាភាសាអង់គ្លេសតាមកម្រិតផ្សេងៗគ្នា ដូចជាភាសាអង់គ្លេសបោះពុម្ពលើកទី៣ថ្នាក់មូលដ្ឋានថ្នាក់បឋម គ្រួសារនិងមិត្តថ្នាក់ទី១ ។ សិស្សរៀនភាសាអង់គ្លេស១១នាក់ ជានិស្សិតអាហារូបករណ៍ឧត្តមសិក្សាសាកលវិទ្យាល័យ។ យើងផ្តល់ការសិក្សាភាសាអង់គ្លេសដល់កុមារីនៅក្នុងមណ្ឌល គឺបត់បែនតាមកម្មវិធីសិក្សានៅសាលារដ្ឋរបស់ពួកគាត់ ព្រោះថាមានក្មេងខ្លះរៀនវេនព្រឹក និងខ្លះទៀតរៀនវេនរសៀល។ លទ្ធផលសម្រេចបាន ល្អប្រសើរលើសផែនការ។ យើងបានបែងចែកការបង្រៀនភាសាអង់គ្លេសជា២ក្រុម បង្រៀនក្មេងធំៗប្រចាំថ្ងៃ និងបង្រៀនក្មេងតូចៗនៅចុងសប្តាហ៍ដែលបង្រៀនដោយអតីតជនរងគ្រោះ ដែលបានបញ្ចប់បរិញ្ញាបត្រភាសាអង់គ្លេស។ យើងមិនអាចបង្រៀនក្មេងតូចៗរាល់ថ្ងៃបានទេដោយសារបញ្ហាពេលវេលា។

- ១៦នាក់ បានសមាហរណកម្មត្រឡប់ទៅគ្រួសារនៅមូលដ្ឋានតាមសហគមន៍វិញ។
- ៦៩នាក់ កំពុងបន្តសិក្សាភាសាអង់គ្លេស។
  - ១៩នាក់ បានបញ្ចប់ថ្នាក់លែត្សហ្គោIII បន្តទៅគ្រួសារនិងមិត្តភក្តិ ៨នាក់បានបញ្ចប់ថ្នាក់ដំបូង បន្តទៅថ្នាក់បឋម។
  - ៨នាក់ ជាសិស្សពូកែបានទទួលរង្វាន់លើកទឹកចិត្តនិងបណ្ណសរសើរ។

សកម្មភាពនៃការបង្រៀនភាសាអង់គ្លេសនៅក្នុងថ្នាក់







## ការបង្រៀនកុំព្យូទ័រ

ជំនាញកុំព្យូទ័រ គឺជាចំណេះដឹង និងសមត្ថភាព ប្រើប្រាស់កុំព្យូទ័រ និងបច្ចេកវិទ្យា សម្រាប់ជីវិតការងារប្រចាំថ្ងៃ ការសិក្សា និងការកំសាន្តផ្សេងៗ។ អាហ្វេស៊ីប កម្ពុជា ផ្តល់ការបង្រៀនជំនាញកុំព្យូទ័រ ដល់កុមារីដែលយើងធ្វើការជាមួយ ដើម្បីជាប្រយោជន៍ដល់ពួកគាត់អាចយកវាទៅប្រើប្រាស់សម្រាប់ការងារប្រចាំថ្ងៃបាន នៅពេលពួកគាត់ធំឡើង។

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារី៧០នាក់ នឹងទទួលបានការសិក្សាកុំព្យូទ័រ។

### លទ្ធផលយើងសម្រេចបាន

កុមារី៦១នាក់ សិក្សាកុំព្យូទ័រ កម្មវិធីវាយអត្ថបទភាសាខ្មែរ និងអង់គ្លេស អ៊ឹមអេសវើដ( MS Word ) អ៊ឹមអេសអ៊ិចសែលនិងផាវើភ័ញ( MS Excel and PowerPoint )អាដូប៍ហ្វូតូសប( Adobe Photoshop ) អាដូប៍ហ្លាស់( Adobe Flash ) អ៊ីនធឺណែតនិងអ៊ីម៉ែល។ ការសិក្សាកុំព្យូទ័រនៅក្នុងមណ្ឌល ប្តូរវេនតាមការសិក្សាចំណេះដឹងទូទៅនៅសាលារដ្ឋ កុមារីមួយចំនួនសិក្សាពេលព្រឹក និងមួយចំនួនទៀតពេលរសៀល។ លទ្ធផលសម្រេចបានតិចជាងផែនការរំពឹងទុក ព្រោះបញ្ហាពេលវេលា (សាលារដ្ឋ) ខ្វះធនធាន យើងផ្តោតលើការបង្រៀនកុមារីធំជាងតូចៗ៖

- ៧នាក់ បានសមាហរណកម្មទៅគ្រួសារវិញ នៅមូលដ្ឋានតាមសហគមន៍។
- ៥៤នាក់ កំពុងបន្តសិក្សាកុំព្យូទ័រ
- ១៧នាក់ បានបញ្ចប់ការសិក្សាដោយជោគជ័យ លើកម្មវិធីអ៊ឹមអេសវើដ (៦) អ៊ិចសែលនិងផាវើភ័ញ (២) អាដូប៍ ហ្វូតូសប (១នាក់) និងអ៊ីនធឺណែតនិងអ៊ីម៉ែល (៨) បានទទួលវិញ្ញាបនបត្របញ្ជាក់ការសិក្សា។
- ៨នាក់ ជាសិស្សពូកែទទួលបានទទួលលិខិតសរសើរនិងរង្វាន់លើកទឹកចិត្ត។

ថ្នាក់រៀនវាយអក្សរ





ថ្នាក់រចនាផ្សេងៗ



## បណ្ណាល័យ

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារី៨០នាក់ នឹងចូលអានសៀវភៅ និងធនធានសិក្សាផ្សេងៗ ចំនួន៣៣០ដង នៅក្នុងបណ្ណាល័យមណ្ឌលទុំឌី។

## លទ្ធផលយើងសម្រេចបាន

កុមារីចំនួន៨៨នាក់ បានចូលអានសៀវភៅ និងធនធានសិក្សាផ្សេងៗ ៣៣៥ដង នៅក្នុងបណ្ណាល័យមណ្ឌលទុំឌី។

បណ្ណាល័យយើងបានចុះឈ្មោះជាសមាជិកនៃសមាគមបណ្ណាល័យកម្ពុជា។

យើងបានផ្តល់វគ្គបណ្តុះបណ្តាលខ្លីអំពីសារប្រយោជន៍នៃការអានសៀវភៅ ដល់ក្មេងៗស្នាក់នៅក្នុងមណ្ឌលទុំឌី។

យើងបានដាក់សៀវភៅបន្ថែមជាច្រើនក្នុងបណ្ណាល័យ ជាប្រយោជន៍ឱ្យក្មេងៗមានជម្រើសច្រើនក្នុងការអាន។ យើងក៏បានរៀបចំតុបតែងលម្អក្នុងបណ្ណាល័យដោយការដាក់ផ្ទាំងសៀវភៅនិងដើមរុក្ខជាតិបន្ថែម។

សកម្មភាពក្មេងៗចូលអានសៀវភៅក្នុងបណ្ណាល័យ



## កម្មវិធីលើកកម្ពស់សេដ្ឋកិច្ច

ទិសដៅសំខាន់សម្រាប់យុវនារី-កុមារីម្នាក់ៗ គឺសម្រេចឱ្យបានស្វ័យឯករាជ្យភាព។ នៅដំណាក់កាលនេះ ពួកគាត់ដែលទទួលផលពីកម្មវិធី គឺបានកាត់បន្ថយការពឹងផ្អែកលើអង្គការអាហ្វេស៊ីប ព្រោះពួកគាត់អាចមានលទ្ធភាពផ្តល់ឱ្យសង្គមវិញខ្លះៗ តាមរយៈការជួយដល់យុវនារី-កុមារីដទៃទៀត ដែលកំពុងឆ្លោះមកកាន់ដំណាក់កាលនេះដែរ។ នៅពេលយុវនារី-កុមារីមានវឌ្ឍនភាពលើការស្តារ អប់រំ និងបណ្តុះបណ្តាល យើងចាប់ផ្តើមនីតិវិធី ធ្វើសមាហរណកម្មពួកគាត់ទៅ រស់នៅតាមសហគមន៍ធម្មតាវិញ ក្នុងន័យនេះគឺពួកគាត់ធ្វើជាកូនជាង ឬហាត់ការ ឬបង្កើតមុខរបរខ្លួនឯង។

## ហេតុអ្វីបានជាយើងធ្វើការងារនេះ?

យុវនារីចាប់ផ្តើមធ្វើការជាកូនជាង ឬហាត់ការ ឬបង្កើតមុខរបរខ្លួនឯង ដោយប្រើប្រាស់ជំនាញដែលពួកគាត់បានសិក្សាដើម្បីរកប្រាក់ចំណូល។ ពួកគាត់ចាប់ផ្តើមរៀនរស់នៅដោយឯករាជ្យភាព គ្រប់គ្រងថវិកានិងការចំណាយផ្សេងៗខ្លួនឯង ជាចំណុចចាប់ផ្តើមធ្វើឱ្យបានសម្រេចនូវឯករាជ្យភាពហិរញ្ញវត្ថុ តាមរយៈនិរន្តភាពអាជីព(មុខរបរ)។

## តើធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ?

យុវនារីបានបញ្ចប់ការសិក្សាដោយជោគជ័យលើជំនាញបានជ្រើសរើស  បានធ្វើសមាហរណកម្មជាមួយការឧបត្ថម្ភការងារ និងបង្កើតមុខរបរខ្នាតតូច ដោយប្រើប្រាស់ជំនាញបានសិក្សា ដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារ។ ពួកគាត់ចាប់ផ្តើមដំណើរការឯករាជ្យភាពហិរញ្ញវត្ថុ តាមរយៈដំណោះស្រាយនិរន្តរភាពមុខរបរ។

## អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាយុវនារី១៤នាក់ នឹងធ្វើសមាហរណកម្ម ជាមួយការឧបត្ថម្ភការងារ និងមុខរបរ ក្រោយពីបញ្ចប់ការសិក្សាដោយជោគជ័យលើជំនាញបានជ្រើសរើស។ យើងឧបត្ថម្ភសម្ភារបង្កើតមុខរបរ ចំពោះការធ្វើសមាហរណកម្មជាមួយមុខរបរខ្នាត់តូច និងឧបត្ថម្ភថ្លៃរស់នៅប្រចាំខែរយៈពេល៣ខែ ចំពោះសមាហរណកម្មជាមួយការងារប្រើប្រាស់ជំនាញដែលបានសិក្សា ។ យើងបន្តតាមដានយ៉ាងទៀងទាត់លើ បញ្ហាសុខភាព ការពិគ្រោះយោបល់ចិត្តសង្គម ប្រឹក្សាបឋមលើមុខរបរ និងការងារ ផ្តល់ការឧបត្ថម្ភបន្ថែមក្រោយសមាហរណកម្មតាមតម្រូវការជាក់ស្តែងលើករណីនីមួយៗ។

## លទ្ធផលយើងសម្រេចបាន

មានកុមារីចំនួន៤៣នាក់ បានសមាហរណកម្មជាមួយការឧបត្ថម្ភការងារ មុខរបរខ្នាតតូច និងអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌលជាគ្រួសារ។ លទ្ធផលសម្រេចបានល្អលើសផែនការ។ ប្រភេទសមាហរណកម្មៈ

- ៥នាក់ បានសមាហរណកម្មជាមួយការឧបត្ថម្ភមុខរបរខ្នាតតូច។
- ១០នាក់ បានសមាហរណកម្មជាមួយការឧបត្ថម្ភការងារ។
- ២៤នាក់ បានសមាហរណកម្មជាមួយការឧបត្ថម្ភអាហារូបករណ៍ស្នាក់នៅក្រៅមណ្ឌល។
- ៤នាក់ បានសមាហរណកម្មទៅគ្រួសារដោយមិនទាន់ឧបត្ថម្ភ។

- ៩៨នាក់ បានទៅលេងគ្រួសារចំនួន១៩៥ដង។ ១៥៣ដង ទៅលេងគ្រួសារនៅតាមសហគមន៍ និង៤២លើកគ្រួសារសាច់ញាតិមកលេងនៅមណ្ឌលទុំឪ។
- ៣៤នាក់ ចូលថ្មីបានទទួលការរៀបចំផែនការអនាគត។
- ៨៦នាក់ ករណីសមាហរណកម្មសកម្ម បានទទួលការតាមដានបន្ត៣៧១ដង ទាំងផ្ទាល់ និងតាមទូរស័ព្ទ។
- ៧នាក់ ករណីសមាហរណកម្ម បានឧបត្ថម្ភបន្ថែម លើការថែទាំសុខភាព១ និងគួចដៃអាពាហ៍ពិពាហ៍៦នាក់។

ការវាយតម្លៃគ្រួសារមុនសមាហរណកម្ម



ការឧបត្ថម្ភការសិក្សា



ឧបត្ថម្ភការចិញ្ចឹមគោ



## កម្មវិធីបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ (សែន)

**សែន**គឺជាការចងក្រងបណ្តាញសមាជិក បានស្តារសះស្បើយពីរបួសផ្លូវកាយ ផ្លូវចិត្តដោយជោគជ័យ និងបានសមាហរណកម្មទៅតាមសហគមន៍វិញនៅទូទាំងប្រទេសកម្ពុជា ក្នុងគោលបំណងលើកទឹកចិត្ត និងសុខមាលភាពសង្គមដល់អតីតជនរងគ្រោះ បញ្ជ្រាប និងបង្កើនការយល់ដឹងដល់សាធារណៈជន ដើម្បីស្វែងរកដំណោះស្រាយឱ្យបានប្រសើរ។ សមាជិក**សែន**នីមួយៗដើរតួនាទីយ៉ាងសំខាន់ ជាអ្នកធ្វើការផ្លាស់ប្តូរនៅតាមសហគមន៍ពួកគាត់ តាមរយៈការពាំនាំ សម្លេងជនរងគ្រោះ ស្វែងរកដំណោះស្រាយ។

### ហេតុអ្វីបានជាយើងធ្វើការងារនេះ?

កម្មវិធី**សែន**បានបញ្ចូលសហសម្លេងរបស់សមាជិកជាផែនការសកម្មភាពទិសដៅ ស្របតាមគោលដៅគន្លឹះ "***លើកទឹកជនរងគ្រោះ ឱ្យក្លាយជាអតីតជនរងគ្រោះ និងលើកទឹកចិត្តអតីតជនរងគ្រោះ ឱ្យក្លាយជាផ្នែកមួយ នៃដំណោះស្រាយ***"។ អតីតជនរងគ្រោះគឺជាអ្នកធ្វើការផ្លាស់ប្តូរដ៏ឆ្នើមនៅក្នុងវិស័យការងារនេះ ពួកគាត់ជានិមិត្តរូប ដែលអាចឱ្យជនរងគ្រោះដទៃទៀតយកគំរូតាម នូវវីរភាពអង់អាចក្លាហានរបស់ពួកគាត់។

### តើធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ?

សមាជិកនៃកម្មវិធីបណ្តាញលើកកម្ពស់អតីតជនរងគ្រោះធ្វើកាងារ ជួយគាំទ្រដល់អ្នកទទួលផលពីកម្មវិធី ទាំងនៅក្នុងមណ្ឌល និងនៅមូលដ្ឋានតាមសហគមន៍។

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាយើងនឹងជ្រើសរើសយុវនារី ចូលជាសមាជិក**សែន**ចំនួន**៧៩**នាក់។ ៥៩នាក់ ស្ថិតិចុងគ្រាឆ្នាំមុន និង ២០នាក់ ជាសមាជិកថ្មីឆ្នាំ២០២៤។

### លទ្ធផលយើងសម្រេចបាន

**សែន**មានសមាជិក**៦៦**នាក់។ ៥៩នាក់ ជាសមាជិកចុងគ្រាពីឆ្នាំមុន និង៧នាក់ជាសមាជិកថ្មី។ យើងបានរៀបចំប្រជុំអាហារសាមគ្គីជាមួយសមាជិក**សែន**បានទៀងទាត់ ក្នុងគោលបំណងចែករំលែកបទពិសោធន៍ បញ្ហាប្រឈម បច្ចុប្បន្នភាពការងារ**សែន** និងពង្រឹងទំនាក់ទំនងសមាជិក។

- សមាជិក**សែន**បានជួយដល់ការងារបណ្តាកម្មវិធីទាំងឡាយដូចជា ស្តារនីតិសម្បទា អប់រំនិងបណ្តុះបណ្តាល ជំនួយនីតិកម្ម និងសមាហរណកម្ម ជាដើមទាំងនៅក្នុងមណ្ឌល និងនៅតាមសហគមន៍។
- បានបោះឆ្នោតប្រចាំឆ្នាំដោយសេរី និងយុត្តិធម៌ ១លើកនៅខែមិថុនា ឆ្នាំ២០២៤ ដោយមានយុវនារី-កុមារីចូលរួមចំនួន៨២នាក់ ដើម្បីជ្រើសរើសប្រធានក្រុមដឹកនាំថ្មីជាតំណាងពួកគាត់ តាមឆន្ទៈ ដើម្បីធ្វើជាតំណាងពាំនាំនូវសម្លេងនៃសេចក្តីត្រូវការរបស់ពួកគាត់នៅមណ្ឌលទុំឌី។ ៥នាក់ បានជាប់ឆ្នោតជាប្រធានក្រុមដឹកនាំ ។

- ១១៩នាក់ បានបន្តទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ពី**សម្តេចនាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។
- បានប្រជុំ១៦លើក។ ៤លើកជាមួយប្រធានក្រុមដឹកនាំ ដើម្បីគាំទ្រការអនុវត្តសកម្មភាពប្រចាំថ្ងៃពួកគាត់ និង១២ លើកជាមួយសមាជិក**សែន** បុគ្គលិកកម្មវិធី និងកុមារីអំពីបញ្ហាទូទៅ ជួយដោះស្រាយបញ្ហាប្រឈមនានា។
- ១៤៨នាក់ ជាកុមារីបានទទួលឪពុក-ម្តាយធម៌ តាមរយៈការគាំទ្រ ពីមូលនិធិសូលីណា នៅប្រទេសស្វីស។

សមាជិក**សែន**ជាមួយអគ្គនាយិកា



វេទិការសាធារណៈអំអីការងារអាហ្វេស៊ីប



ការប្រជុំអាហារសាមគ្គី



# អំពីបុគ្គលិក និងការគ្រប់គ្រងគម្រោង

## អំពីបុគ្គលិក

បុគ្គលិក៣៤នាក់ បម្រើការនៅអង្គការ អាហ្វេស៊ីប កម្ពុជា ក្នុងឆ្នាំ២០២៤ មាននារី២០ និងបុរស១៤នាក់។ ៨៤%នៃបុគ្គលិកនារីជាអតីតជនរងគ្រោះ។ យើងលើកទឹកអតីតជនរងគ្រោះ ឱ្យក្លាយជាផ្នែកមួយនៃដំណោះស្រាយ ព្រោះថាអតីតជនរងគ្រោះគឺជាអ្នកធ្វើការផ្លាស់ប្តូរដ៏ឆ្នើមនៅក្នុងវិស័យការងារនេះ ពួកគាត់ជានិមិត្តរូបឱ្យជនរងគ្រោះដទៃទៀតយកគំរូតាម នូវវីរភាពអង់អាចក្លាហានរបស់ពួកគាត់។ បុគ្គលិកជាអតីតជនរងគ្រោះ បច្ចុប្បន្នកំពុងកាន់តួនាទីការងារជាសមាជិកគណៈគ្រប់គ្រងជាន់ខ្ពស់ ដូចជាប្រធានកម្មវិធី **សែន** មណ្ឌល គិលានុបដ្ឋាយិកា អប់រំនិងបណ្តុះបណ្តាល អ្នកសម្របសម្រួលអាហារូបករណ៍ឧត្តមសិក្សានិងជំនាញវិជ្ជាជីវៈ ផ្នែកចិត្តសាស្ត្រ លើកកម្ពស់សេដ្ឋកិច្ច បុគ្គលិកថែទាំ ចុងភៅ ហិរញ្ញវត្ថុ អ្នកសម្របសម្រួលឪពុក-ម្តាយធម៌ និងជំនួយការផ្នែកនីតិកម្ម ។

## អំពីការគ្រប់គ្រងគម្រោង

យើងបានរៀបចំប្រជុំជាទៀងទាត់ ជាមួយបណ្តាប្រធានកម្មវិធី ក្នុងគោលបំណងចែករំលែក វឌ្ឍនភាពការងារ នៃកម្មវិធីនីមួយៗ ទទួលយកការឆ្លើយតបនៃការតាមដានការអនុវត្តសកម្មភាពការងារពីអង្គប្រជុំមុនៗ ទទួលយកបច្ចុប្បន្នភាពការងារ បង្កើតក្រុមការងារ ឬផែនការសកម្មភាពការងារ តាមតម្រូវការជាក់ស្តែង លើសកម្មភាពជាក់លាក់ណាមួយ។ល។ នេះជាផ្នែកមួយនៃការកសាងស្មារតីក្រុមការងារ ការកសាងសមត្ថភាពបុគ្គលិក និងការគ្រប់គ្រងគម្រោងសម្រាប់បុគ្គលិក។ កម្មវិធីនីមួយៗបានប្រជុំជាមួយបុគ្គលិករបស់ខ្លួន ក្នុងគោលបំណងដូចគ្នា។

ប្រធានកម្មវិធី-ផ្នែកនីមួយៗត្រូវធ្វើផែនការសកម្មភាពនិងថវិកាប្រចាំខែ សម្រាប់ការអនុវត្តសកម្មភាពការងារ អនុលោមតាមផែនការមេ ដាក់ជូនប្រធានខ្សែបណ្តោយពិនិត្យសម្រេច នៅរាល់ថ្ងៃទី២៥នៃខែនីមួយៗ និងធ្វើរបាយការណ៍សកម្មភាពការងារបានអនុវត្តដាក់ជូនប្រធានខ្សែបណ្តោយជារៀងរាល់សប្តាហ៍ទី១នៃខែបន្ទាប់។ សប្តាហ៍ទី៤ប្រចាំខែ បុគ្គលិកកម្មវិធី-ផ្នែកនីមួយៗត្រូវធ្វើបច្ចុប្បន្នភាពកំណត់ត្រាការងារ ចូលក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារីនីមួយៗ ដើម្បីបញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រសម្រាប់ធ្វើរបាយការណ៍ផ្ទៃក្នុង និងរបាយការណ៍ផ្ញើចេញក្រៅ។

### ការលើកទឹកចិត្តបុគ្គលិក







## ការកសាងសមត្ថភាពបុគ្គលិក

- យើងបានផ្តល់ការកសាងសមត្ថភាពបុគ្គលិក តាមរយៈវគ្គបណ្តុះបណ្តាលខ្លីៗរួមមាន ការអន្តរាគមន៍ជាក្រុម វិបស្សនាកម្មដ្ឋាន(សមាធិ) សិក្ខាសាលាអេអាយ អាយប្លូមីង ការព្យាបាលសុខភាពផ្លូវចិត្ត រោគសញ្ញាសំខាន់ៗនៃបញ្ហាសុខភាពផ្លូវចិត្តនៅកម្ពុជា គឺភាពតានតឹង ការធ្លាក់ទឹកចិត្ត បាក់ស្បាត LGBT និងវគ្គបណ្តុះបណ្តាលអំពីការប៉ះដង្ហិចផ្លូវចិត្ត។

### សិក្ខាសាលាពិគ្រោះយោបល់ប្រចាំឆ្នាំ



### ការបញ្ចប់វគ្គបណ្តុះបណ្តាលខ្លីស្ដីពីការប៉ះដង្ហិចផ្លូវចិត្ត



លទ្ធផលសម្រេចបានខាងលើ អនុលោមតាមចក្ខុវិស័យ និងទិសដៅស្នូល ការផ្តល់ការថែទាំ និងធានាបាននូវសិទ្ធិយុវនារី-កុមារីរងគ្រោះ និងងាយរងគ្រោះ ដោយអំពើទាសភាព តាមរយៈការស្តារ ការអប់រំ បណ្តុះបណ្តាល និងសមាហរណកម្មដោយជោគជ័យ ត្រឡប់ទៅសង្គមវិញ ដោយឯករាជ្យភាពហិរញ្ញវត្ថុ និរន្តរភាព និងភាពថ្លៃប្រឌិត។ យើងអនុវត្តការងារនេះ ដោយជួយជ្រោមជ្រែង និងបង្ហាត់បង្រៀនពួកគាត់ អំពីឯករាជ្យភាពហិរញ្ញវត្ថុ តាមរយៈនិរន្តភាពមុខរបរ។ បន្ទាប់មកយើងស្វាគមន៍ លើកទឹកចិត្តឱ្យពួកគាត់ ក្លាយជាផ្នែកមួយរបស់បណ្តាញលើកកម្ពស់អតីតៈជនរងគ្រោះ ។

## ផែនការសកម្មភាព ឆ្នាំ២០២៥

១០៣នាក់ នឹងបានទទួលសេវាស្តារនីតិសម្បទា ជម្រកសុវត្ថិភាព រួមទាំងអាហារូបត្ថម្ភ ថែទាំសុខភាព ពិគ្រោះយោបល់ចិត្តសង្គម និងជំនួយផ្នែកច្បាប់ នៅមណ្ឌលទុំឌី ឆ្នាំ២០២៥។ ៧៣នាក់ ស្ថិតិចុងគ្រា និង៣០នាក់ ចូលថ្មីឆ្នាំ២០២៥។

- បន្តតាមដានការអនុវត្តនីតិវិធីព្រហ្មទណ្ឌចំពោះអនិតិជនរងគ្រោះអាយុក្រោម១០ឆ្នាំ មិនគួរចូលសវនការនៅតុលាការ។

**២៤០នាក់** នឹងទទួលបានអាហារូបករណ៍ក្រោមឧត្តមសិក្សា ឧត្តមសិក្សាសាកលវិទ្យាល័យ និងជំនាញវិជ្ជាជីវៈ។

**៣៨នាក់** នឹងសមាហរណកម្មជាមួយការឧបត្ថម្ភការងារ មុខរបរខ្នាតតូច និងទៅគ្រួសារវិញ ជាមួយការឧបត្ថម្ភអាហារូបករណ៍ក្រោមឧត្តមសិក្សា បន្តការសិក្សានៅមូលដ្ឋាន តាមសហគមន៍។

៨១នាក់ ជាសមាជិកបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ នឹងជួយគាំទ្រការងារផ្សេងៗ នៅក្នុងមណ្ឌលនិងសហគមន៍។ ក្នុងនោះ១៥នាក់ជាសមាជិកចូលថ្មីឆ្នាំ២០២៥។

**វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពបុគ្គលិក**

- ១វគ្គសិក្សាខ្លី អំពីការគ្រប់គ្រងភាពតានតឹង
- ១វគ្គសិក្សាខ្លី អំពីភាពជាអ្នកដឹកនាំ និងជំនាញសរសេររបាយការណ៍
- បុគ្គលិកជាអតីតជនរងគ្រោះសិក្សាភាសាអង់គ្លេសតាមអនឡាញបង្រៀនដោយគ្រូជិល្លនិងលិន្ដាគ្រូស្ម័គ្រចិត្ត
- ១វគ្គសិក្សាខ្លី អំពីការការរៀបចំនិងគ្រប់គ្រងចំណីអាហារ និងចុងភៅ
- ១វគ្គសិក្សាខ្លី អំពីការងារទម្រង់សមាហរណកម្មនិងការងារសមាហរណកម្ម( គ្រូបង្គោលពីក្រសួងសង្គមកិច្ច )
- ១វគ្គសិក្សាខ្លី អំពីការរចនាក្រាហ្វិក( Graphic design )សម្រាប់គ្រូកុំព្យូទ័រ
- ១ទស្សនកិច្ចទៅតាមមន្ទីរពេទ្យបរទេសសម្រាប់បុគ្គលិកកម្មវិធីសុខភាព
- បន្តពិនិត្យកែលម្អធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងនីតិវិធីបុគ្គលិក ដើម្បីឆ្លើយតបតាមស្ថានភាពបច្ចុប្បន្ន



# ក្រុមប្រឹក្សាភិបាល



**លោក ក្លូដ ហីលដែនប្រែន្ទ**

ប្រធានក្រុមប្រឹក្សាភិបាល

អនុប្រធាន មូលនិធិសូលីណា

ស្ថាបនិកក្រុមហ៊ុន វីនី & វីនី ហ្សា



**លោកស្រីម៉ម សុម៉ាលី**

សមាជិកក្រុមប្រឹក្សាភិបាល

សកម្មជនសិទ្ធិមនុស្ស

ស្ថាបនិក និងអគ្គយិកា អាហ្វេស៊ីប



**លោក ឆានឌូ ប៊ីនឌី**

សមាជិកក្រុមប្រឹក្សាភិបាល

ប្រធានប្រតិបត្តិករធនាគារ ទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី

និងសមាជិកជាក្រុមប្រឹក្សាភិបាលអង្គការ ប្រូចិក ផ្ទួឈ័រ



**លោកស្រី ទ៉ាន់ ស៊ីណា**

សមាជិកក្រុមប្រឹក្សាភិបាល

សកម្មជនសិទ្ធិមនុស្ស

សហនាយិកាកម្មវិធី

ប្រធានកម្មវិធីអតីតជនរងគ្រោះ



**ក. អាណាលីន ម៉ខ័ដ**

សមាជិកក្រុមប្រឹក្សាភិបាល

តារាសម្ដែងហូលីវ៉ូដ សកម្មជនសិទ្ធិមនុស្ស និងស្ថាបនិកព្យុះស្នេហ៍

# សង្ខេបមូលនិធិទទួលបាន និងការចំណាយ




| ចំណាយ | សរុប (USD) | |
|---|---|---|
| រដ្ឋបាល | 51,048.94 | 8% |
| សេវាស្តារនីតិសម្បទា | 332,705.29 | 52% |
| អប់រំនិងបណ្តុះបណ្តាល | 111,450.18 | 18% |
| លើកកម្ពស់សេដ្ឋកិច្ច (សមាហរណកម្ម) | 62,471.71 | 10% |
| សែន (លើកកម្ពស់អតីតជនរងគ្រោះ) | 77,601.84 | 12% |
| សរុប | **635,277.96** | |



# ម្ចាស់ជំនួយ

## រាជរដ្ឋាភិបាលកម្ពុជា

Foundation SOLYNA — Saving children from sexual traffic

PROJECT FUTURES — TRANSFORMING LIVES

HEART MOTHERS — Sending love to child survivors of sex trafficking

Individual Donors

THE ORPHANED STARFISH FOUNDATION

សម្រស់ធម្មជាតិ

DAUN PENH CAMBODIA GROUP

NH Finance Cambodia

THE CHURCH OF JESUS CHRIST OF LATTER-DAY SAINTS

**The Royal Government of Cambodia Provides ongoing support of:**

- អង្ករ១៤,៤តោនសម្រាប់រយៈពេល១២ខែ។
- ២៤០,០០០,០០០.00រៀលឧបត្ថម្ភម្ហូបប្រចាំថ្ងៃសម្រាប់រយៈពេល១២។
- ១៤២,៨០០,០០០.០០រៀលឧបត្ថម្ភប្រាក់ហោប៉ៅប្រចាំខែដល់កុមារី១១៩នាក់សម្រាប់រយៈពេល១២ខែ។
- ៥០,០០០.០០ដុល្លារអាមេរិកជួយប្រចាំឆ្នាំ សម្រាប់ចំណាយលើការខ្វះខាតផ្សេងៗរយៈពេល១២ខែ។
- ឧបត្ថម្ភអាហារូបករណ៍(ថ្លៃសាលា)ដល់និស្សិតឧត្តមសិក្សាសាកលវិទ្យាល័យចំនួន២០នាក់
- បុគ្គលិកជាអតីជនរងគ្រោះ៤នាក់បានបញ្ចូលជាមន្ត្រីរាជការស៊ីវិល(មន្ត្រីរដ្ឋាភិបាល)



អរគុណ